ផង ដោយរវល់តែពីបញ្ហាធំៗនៅខាងក្រៅ ឯណោះមែនទេ ?

-ជាកិច្ចការផ្ទាល់ខ្លួនរបស់ខ្ញុំទេតើ! មានដែលទៅប៉ះពាល់លើអ្នកណា ម្ដេចក៏លោកមកចោទយ៉ាងនេះ លោកជាអ្វីទៅ ?

-ខ្ញុំជាអធិការពិសេស ក៏មានភារកិច្ចក្នុងការតាមដានជនទុច្ចរិតអីចឹងដែរ ប៉ុន្តែខ្ញុំមិនធ្វើឱ្យប៉ះពាល់ដល់ជនសុចរិតត្រឹមត្រូវ ដែលមិនបានប្រព្រឹត្តល្មើសនឹងច្បាប់រដ្ឋនោះជាដាច់ខាត ឯចំណែកពួកថៅកែត្រូវតែខ្ញុំប៉ះពាល់ខ្លះដោយខានមិនបាន សុំអភ័យទោស......

គ្រាន់តែឮឈ្មោះអធិការពិសេស ថៅកែនិងភរិយាចង់ហោះពីកៅអី ព្រោះនៅក្នុងក្រុងព្រះសីហនុនេះ គេមិនធ្លាប់ឮឈ្មោះអធិការពិសេសនេះទាល់តែសោះ ។

ថាវីប្រឹងទប់ចិត្តកុំឱ្យញាប់ញ័រពេក ហើយសួរវិញថា ÷

-ចុះពួកខ្ញុំនេះបានប្រព្រឹត្តអ្វីខ្លះផ្ទុយនឹងច្បាប់សម្រាប់រដ្ឋ ? ការបើកបារនេះខ្ញុំមានច្បាប់ មានបាតង់ត្រឹមត្រូវណាស់ ពុំដែលមានគេចវេះក្នុងការបង់ពិន័យជូនរាជការដល់ម្ដងណាទេ ម្ដេចក៏លោកមកចោទពួកខ្ញុំដូច្នេះទៅវិញ ?

-ចំណែករបររកស៊ីរត់ពន្ធដោយលួចលាក់ ដោយឃុបឃិតជាមួយជនបរទេសនោះ តើច្បាប់សម្រាប់រដ្ឋមានចែងឱ្យពួកថៅកែធ្វើឬទេ ? ណ្ហើយ ! ដើម្បីកុំឱ្យខូចពេលវេលា និងដើម្បីកុំឱ្យស្រវាំងភ្នែកយូរទៀត ត្រូវថៅកែប្រាប់ខ្ញុំតាមត្រង់មក តើថៅកែពីរនាក់ពីហុងកុងមកទាក់ទងពីកិច្ចការអ្វីជាមួយ ?

ថាវី នារីជើងឆើតខាងកលល្បិចអន្តរជាតិ ញាក់មុខបន្តិចទើប



តប ÷

-ថៅកែហុងកុងណាអញ្ចេះ ? ខ្ញុំដូចជាពុំបានចាប់ភ្លឹកទាល់តែសោះ.......

-បើអ្នកស្រីថាវីមិនស្គាល់ទេ ចាំខ្ញុំប្រាប់ឈ្មោះក៏បានដែរ ម្នាក់ឈ្មោះស៊ីបេ ហើយម្នាក់ទៀតឈ្មោះហ្វឡុង ជាអ្នកទាក់ទងពាណិជ្ជកម្មសម្ងាត់រវាងហុងកុងភ្នំពេញ ម៉េចអ្នកស្រីនឹកឃើញហើយឬនៅ ?

ថាវីធ្វើមុខមឹងម៉ាំង ព្រមទាំងឆ្លើយតបធ្វើហី ÷

-ខ្ញុំមិនស្គាល់វាពីរនាក់នោះទេ........ បើលោកស្គាល់មុខជនពីរនាក់នោះហើយ ម៉េចក៏មិនចាប់វានោះទៅ ម៉េចក៏មករំខានខ្ញុំឯណោះវិញ ?

-ការចាប់ជនពីរនាក់នោះ វាគ្មានលំបាកអ្វីទេ ប៉ុន្តែភ័ស្តុតាងនិងរបស់ជាច្រើនត្រូវបាត់ស្រមោល ហើយជាពិសេសចៅហ្វាយធំរបស់ពួកអ្នកស្រី ដែលរស់យ៉ាងច្រខែងនៅឯភ្នំពេញ នឹងត្រូវក្រសួងយើងរកឫសគល់លែងឃើញតែម្ដង ។ ឥឡូវសុំអ្នកស្រីនិងថៅកែឆ្លើយត្រង់ៗមក កាលណាបើអ្នកស្រីនិងថៅកែប្រកែកពុំព្រមសារភាពតាមត្រង់ទេ បានសេចក្ដីថាអ្នកស្រីនិងថៅកែ បង្ខំឱ្យក្រសួងយើងប្រើមធ្យោបាយក្ដៅតែម្ដង ។

លោកអធិការពិសេស ដែលយើងស្គាល់ជាក់ជាបុរសពិសេស ដ៏កំពូលក្នុងក្រសួងសម្ងាត់របស់ជាតិយើងនោះឯង បានផ្អាកប្រយោគមួយភ្លែត រួចទើបបន្តទៀត ÷

-ថៅកែពីរនាក់មកពីហុងកុងនោះ តើមកទាក់ទងពីរឿងនាំរបស់

វត់ពន្ធចូលមកតាមផែនេះមែនទេ ?

-បាសទេ ! ខ្ញុំមិនបានទឹកដល់ទាល់តែសោះ.....

-ប៉ុន្តែខ្ញុំបានដឹងមុនរួចអស់ទៅហើយ ថាថៅកែនិងអ្នកស្រីបានរៀបចំគ្រោងការរួចអស់ហើយ ជាមួយថៅកែពីរនាក់នោះ ដោយមានក្រុមធំ ដែលយើងរកមុខមិនទាន់ឃើញមួយទៀត ជួយគាំទ្រតាមផ្លូវងងឹតទៀតផង ដូច្នេះដើម្បីសម្រួលការនេះឱ្យបានធូរស្រាល សុំអ្នកស្រីនិងថៅកែប្រាប់ឱ្យត្រង់មក តើថៅកែធំនៅភ្នំពេញនោះឈ្មោះអី ? ហើយចិនពីរនាក់មកពីហុងកុងនោះ បាននាំអីវ៉ាន់ចូលមកហើយឬនៅ ?

ថៅកែមុយដោយផ្សាភ្នែក ចំពោះរស្មីភ្លើងខ្លាំងពេក ក៏តបដោយកាត់ៗថា ÷

-ការអស់នេះ ខ្ញុំពុំបានដឹងច្បាស់នៅឡើយទេ ប៉ុន្តែពីព្រលប់នេះគ្រាន់តែមានចិនពីរនាក់បានមកស្នើឱ្យខ្ញុំចាំជួបនៅក្នុងបារ វេលាម៉ោង២៣អាធ្រាត្រនេះ បើលោកពុំយល់ទាស់ទេ សូមលោកអញ្ជើញទៅជួបវាជាមួយខ្ញុំចុះ ខ្ញុំមិនប្រកាន់ទេ ព្រោះថាបើការនេះវានឹងមានដូច្នេះមែន ក៏សុំលោកវិនិច្ឆ័យទៅចុះ ខ្ញុំមិនអាចប្រកែកឡើយ.......

និយាយហើយ ថៅកែមុយកេះភរិយាឱ្យនិយាយបន្ត ÷

-ខ្ញុំហ៊ានធានាចំពោះមុខលោកថា បើចិនពីរនាក់នោះ មកនិយាយជាមួយខ្ញុំក្នុងរឿងរត់ពន្ធ ដូចលោកបានចោទមែននោះ នាងខ្ញុំនឹងចាប់វាប្រគល់ជូនលោកភ្លាម មិនបាច់ឱ្យលោកមានការលំបាកឡើយ ប៉ុន្តែបើតាមខ្ញុំយល់ ចិនពីរនាក់នោះមកទាក់ទងនឹងខ្ញុំ ដោយ



ប្រាថ្នាយកស្រីក្មេងល្អ។ ក្នុងបារខ្ញុំទៅលេងសើចទេតើលោក !

លោកអធិការពិសេសបាត់មាត់មួយសន្ទុះ រួចក៏លូកដៃចុចកណ្ដឹងរោទិ៍យ៉ាងវែង ហើយទ្វារពីក្រោយលោកក៏របើកឡើង ស្រមោលមនុស្សម្នាក់ស្ទុះចេញមក ប្ដូរស្រមោលលោកអធិការពិសេសភៀសចូលទៅក្នុងបាត់ភ្លាម ដោយពុំមានឱ្យថៅកែនិងថាវីចំណាំភិនភាគបានឡើយ ។ រំពេចនោះពន្លឺរស្មីបញ្ចាំងក៏រលត់ភ្លឹប ហើយអំពូលវែងក្នុងបន្ទប់នោះទាំងពីរ ក៏ឆេះចិញ្ចែងឡើងភ្លាម បណ្ដាលឱ្យរលាយមហន្តការ ដ៏សូន្យសុងអម្បាញមិញអស់ពីក្នុងបន្ទប់ ក៏លេចរូបលោកស្នងការនៅអង្គុយជ្រងោនឹងមុខ ទាំងសាច់ទាំងឆ្អឹងតែម្ដង ។ ថៅកែមុយនិងនាងថាវីញីភ្នែកចុះឡើងពីរបីដង ទើបថៅកែមុយបន្ទឺសម្លេងតិចៗ ស្ទើរស្ដាប់មិនចង់បាន ÷

-អូ៎........ អម្បាញមិញហ្នឹងគឺព្រះតេជគុណទេ ?

លោកស្នងការសើចពព្រាយ ÷

-បាទថៅកែ ! គឺរូបខ្ញុំហ្នឹងឯង មិនជាការចំឡែកប៉ុន្មានទេ គ្រាន់តែធ្វើឱ្យថៅកែនិងអ្នកស្រីតានតឹងចិត្តបន្តិចបន្តួច ។

ថាវីសម្លក់លោកស្នងការ ដោយភ្នែកទាំងគូយ៉ាងមុត ÷

-ម៉េចក៏លោកចាំបាច់ធ្វើឱ្យខ្ញុំភ័យ ស៊ីងលោះព្រលឹងស្លាប់អីចឹង ? លោកស្គាល់ខ្ញុំយូរហើយ ការណ៍អីៗគួរតែលោកហៅដេញដោលបំភ្លឺតែម្ដងទៅ វាមានទាស់ខុសអីលោក........

-អម្បាញមិញយើងជាមនុស្សមិនបានយោគយល់គ្នា តែឥឡូវយើងបានក្លាយជាអ្នកជិតដិតដូចគ្នា ដូចកាលពីដើមឡើងវិញហើយ

ផ្ទះសុំអ្នកស្រីអញ្ជើញទៅបារវិញចុះ ខ្ញុំអស់មានការអ្វីទៀតហើយ....

ថៅកែមុយបើកភ្នែកធំៗ ÷

-ចុះក្រែងលោកចង់ទៅជួបជាមួយចិនពីរនាក់ពីហុងកុងនោះដែរ។

-មិនបាច់ទេ ! ខ្ញុំអស់មានការសង្ស័យទៀតហើយ សុំថៅកែនិងអ្នកស្រីអញ្ជើញ !...

មានប្រសាសន៍ចប់ហើយ លោកស្នងការដើរមកបើកទ្វារ ឱ្យអ្នកទាំងពីរចេញដោយសុវត្ថិភាព ហាក់ដូចពុំមានជាប់ពិរុទ្ធអ្វីឡើយ ។ ថៅកែនិងអ្នកស្រីត្រេកអរណាស់ ក៏បររថយន្តចេញទៅជាប្រញាប់ ដោយទាំងភ្លេចលាលោកស្នងការយើងផង ។ រថយន្តមកពន្លត់ម៉ាស៊ីននៅពីមុខបារកូឡាប-ស ហើយថាវីនិងថៅកែក៏រត់ចូលទៅជាប្រញាប់ ដោយនៅទីនោះមានភ្ញៀវនិងស្រីបំរើកំពុងតែទាក់ទងគ្នាយ៉ាងសកម្ម ។ ថៅកែដឹកដៃភរិយាចូលទៅក្នុងបាត់ស្រមោល ដោយមិនទាំងបានបញ្ចេញអាកប្បកិរិយា រាក់ទាក់ទទួលភ្ញៀវដូចកាលសព្វមួយដងផង ។ ថៅកែស៊ីបេនិងហ្លួឡាងអង្គុយផឹកស្រានាតុកៀនជញ្ជាំងយ៉ាងស្ងប់ស្ងាត់ រង់ចាំថៅកែនិងថាវីចេញមកជួបសន្ទនាវិញ ។ អង្គុយផឹកទឹកក្រូច រំលងពីតុចិនទាំងពីរប្រហែលជាបីតុ យើងឃើញបុរសពិសេសស្លៀកពាក់សមសួន កំពុងស្ទាបអង្អែលនារីស្រស់ឆើតឆាយម្នាក់ទាំងភ្ញើតភ្ញើន ។

បុរសពិសេសយើងលួកដៃកៀកចង្កេះនារី ដោយបន្ទីវាចាថា ÷

-យប់នេះបងរីកថ្លើមប៉ុនមេឃ ដោយបានអូនសូភីរាក់ទាក់លើសយប់មុនៗ ហើយប្រហែលជាស្អែកនេះបងនឹងត្រូវឆ្នោតជាតិមិនខានទេ



សូភី ជានារីល្អផ្តាច់គេនៅក្នុងបារកូឡាប-សនេះ បានត្រូវយុវអធិការពិសេស លួងលោមជាច្រើនរាត្រីមកហើយ ហើយនាងសូភីក៏កាន់តែទុកចិត្តមិត្តយើងច្រើនឡើងដែរជាលំដាប់ ដោយមកពីបុរសនេះមានប្រាក់កាសចាយជាមធ្យម តែរូបសម្បត្តិគេឆើតមិនចាញ់ត្តកុនហុលីវុតប៉ុន្មានទេ ជាពិសេសនាងសំគាល់ឃើញថាបុរសនេះជាមនុស្សខ្លួនមួយផង ម៉្លោះហើយសូភីក៏ចង់ទាក់ទាញដួងចិត្តគេ ឱ្យបានមកធ្វើជាម្ចាស់ជីវិតនាង គ្រាន់នឹងបានអែបនែបនិស្សរហូតតរៀងទៅ ។

-បងហ្នា ! យើងរាប់អានគ្នាយូរថ្ងៃហើយ តែបងមិនព្រមប្រាប់ឈ្មោះ និងទីលំនៅឱ្យអូនស្គាល់ផងសោះ ឬមួយបងស្រឡាញ់អូនតែបបូរមាត់ក្រៅទេ ?

លោកអធិការមិនស្គាល់ឈ្មោះ វាសភ្នែកភ្នែតទៅតុថៅកែហុងកុងទាំងពីរ រួចទៅកាន់តុភ្ញៀវជាលំដាប់លំដោយ ដើម្បីពិនិត្យជនចំឡែកៗ ដែលបានចូលមកអង្គុយតុជិតៗនោះ ហើយលោកវាសភ្នែកជាចុងក្រោយទៅក្រុមភ្លេង ដែលកំពុងតែប្រគំបទហាក់កញ្ឆេងយ៉ាងភ្ញើតភ្ញើនបែកញើសគឃារ......... ។

-បងភ្លឹកទៅណាហ្នឹង ?

លោកអធិការូបស្អាតថ្មីដៃដែកភ្ញាក់ព្រើត ប្រញាប់លើកកែវទឹកក្រូចមកដាក់ជិតបបូរមាត់ ព្រមទាំងធ្វើជាកែតប ÷

-បងកំពុងភ្ញើតភ្ញើនជាមួយពួកភ្លេង អូនឯងសួរបងថាម៉េចអម្បាញមិញ ?

សូភីញញឹមរលាស់សក់ទៅក្រោយ ÷

-អូននិយាយថា បងមិនព្រមប្រាប់ឈ្មោះ និងទីលំនៅឱ្យអូនបានដឹងសោះ ឬមួយបងនៅតែលាក់នឹងអូនដូច្នេះរហូតទៅ ?

-អ៊ូ ! អីចឹងទេ ! បងមានទៅកំណាញ់អីនឹងអូន ប៉ុន្តែបើអូនមិនសួរសោះ ហើយឱ្យបងហារមាត់ប្រាប់មុន ដូចជាបងហ្នឹងចង់ផ្សាយឈ្មោះឱ្យគេស្គាល់ពេក ។ បងឈ្មោះកិត្តិគុណ ធ្វើការនៅកំពង់ផែ មួយខែបានមួយពាន់ប្លាយរៀល ទីលំនៅបណ្ដោះអាសន្នមិនកំណត់ បើអូនឯងចង់ទៅរកកន្លែងណាក៏ជួបដែរ.......

នារីញញឹមម្ដងទៀត លើកដៃបិចថ្ពាល់លោកអធិការរួបសង្ហារបេ្រិប ÷

-បងកិត្តិគុណចូលចិត្តកំប្លែងលេងម៉្លេះ ! ពាក្យសំដីហូររដឹកដូចទឹកធ្លាក់ពីលើភ្នំ សមជាអ្នកចេះដឹងណាស់. បងកិត្តិគុណហ្នា ! បើបងគ្មានទីលំនៅទេ បងព្រមមករស់រួមសុខទុក្ខជាមួយអូនបានទេ ?

លោកអធិការកិត្តិគុណសើចពព្រាយ ÷

-បងសូមអរគុណណាស់ បើបានអូនមានចិត្តមេត្តាយ៉ាងនេះ ប៉ុន្តែក្រែងបងរកសុភមង្គលឱ្យអូនមិនបានគ្រប់គ្រាន់ណាំ !

-តែអូនពេញចិត្តនឹងរកសុភមង្គលគ្រប់យ៉ាងជូនបងវិញទេតើ......

សូភីមិនទាន់បញ្ចប់ប្រយោគផង ស្រាប់តែមាននារីកូនកាត់ចិនម្នាក់ដើរមកទះស្មាហៅ ដោយសម្លេងប៉ៃឡាំៗថា ÷

-ថៅកែឱ្យហៅទៅក្នុងមួយភ្លែតសូភី !

នារីញូវជ្ញោះ ក៏ងើបពីកៅអី ហើយចាប់ដៃលោកកិត្តិគុណប្រាប់តិចៗ ÷



-បងកុំអាលចេញណាំ ! ខ្ញុំទៅជួបថៅកែមួយភ្លែតសិន.......

មិត្តកិត្តិគុណយើងងក់ក្បាលយល់ព្រមទាំងសោះកក្រោះ តែភ្នែកលោកបានវាត់យ៉ាងរហ័សទៅលើមុខថៅកែហុងកុងទាំងពីរ ដែលកំពុងតែខ្សឹបខ្សៀវគ្នាមិនដឹងពីរឿងអ្វី ។ នារីទាំងពីរឈានចូលទៅក្នុងបាត់មួយសន្ទុះ ទើបថៅកែទាំងពីរងើបដើរចូលទៅតាមក្រោយបណ្ដាលឱ្យលោកអធិការយើង មានការសង្ស័យក្នុងចិត្តជាខ្លាំង ។ តន្ត្រីប្រគុំលាន់ទ្រហឹងសឹងស្ដាប់អ្វីលែងឮ លាយឡំជាមួយសម្លេងមនុស្សសើចសប្បាយខ្មៀវខ្វា ដូចបក្សាបក្សីចាកទ្រនំនាពេលព្រហាម។ លោកអធិការពិសេសកិត្តិគុណ លើកកែវទឹកក្រូចក្រេបមួយក្លឹកជាចុងក្រោយ ហើយក៏ងើបឈរម្យ៉ើងប្រុងនឹងដើរចេញពីតុទៅហើយ ស្រាប់តែនារីពីរនាក់ទំនងជាកូនកាត់ចិន ស្លៀកពាក់ទាន់សម័យហួសខ្នាតដើរមកឈរពីក្រោយខ្នង ដោយដៃឆ្វេងទ្រថាស និងដៃស្ដាំលូកទប់ពីក្រោមថាសដូចគ្នា ហើយនារីម្នាក់ក៏បន្ទឺសម្លេងល្មមតែឮច្បាស់ត្រឹមតែត្រចៀកកិត្តិគុណម្នាក់ឯងប៉ុណ្ណោះ.........

-លោកឈ្មោះលោកកិត្តិគុណមែនទេ ?

សម្លេងនារីស្រួយខ្ទោកដូចអំបុកត្រូវទឹកកក តែគួរឱ្យព្រឺខ្លួន កិត្តិគុណប្រុងបែរមើលមុខនារីម្ចាស់សំនួរឱ្យបានច្បាស់ ប៉ុន្តែ ÷

-មិនបាច់លោកប្រើកាយវិការអ្វីផងទេ ក្រៅពីចម្លើយមកយើងទេ បើលោកមិនព្រមស្ដាប់ លោកនឹងត្រូវស្លាប់ដោយគ្រាប់កាំភ្លើងរបស់យើង នៅពីក្រោមថាសនេះមិនខាន.......

កិត្តិគុណមានចិត្តជាដែកថែប ទឹកដៃប្រយុទ្ធដូចហនុមាន ធ្លាប់ទាំងរុញច្រានបច្ចាមិត្តសព្វទិសទីប្រកបដោយជោគជ័យ មិនដែលភ័យស្លុតចំពោះមុខកាំភ្លើង ការសំឡុតពីបច្ចាមិត្តណាឡើយ ។ អធិការកំឡោះយើង ញញឹមបំប្រឹមពោះសំដីតប ÷

-ខ្ញុំឈ្មោះកិត្តិគុណមែន តើខ្ញុំមានរឿងអីនៅក្នុងបារនេះ ទើបពួកអស់នាងមកកំហែងគម្រាមខ្ញុំយ៉ាងហ្នឹង ? ឬអស់នាងបែបភ័ន្តច្រឡំទេដឹង ?

-ភ័ន្តច្រឡំឬយ៉ាងណា សុំតែលោកធ្វើតាមបញ្ជាពួកយើងចុះ នោះទើបបានសុខខ្លួន ហើយបើរឹងទទឹង លោកនឹងទៅស្គាល់ស្ថាននរកប្រាំពីរជាន់មិនខានទេ ឥឡូវដើរតាមពួកខ្ញុំភ្លាមមក !

គ្មានតក់ស្លុតប៉ុនសរសៃសក់ឡើយ តែដើម្បីឱ្យបានស្គាល់ឫសគល់កូឡាបស មិត្តកិត្តិគុណយើងត្រូវតែប្រតិបត្តិតាមបញ្ជានារីទាំងពីរជាបណ្តោះអាសន្ន ។ នារីម្នាក់បកក្បាលដើរមុខជាអ្នកនាំផ្លូវ បន្ទាប់មកមិត្តយើងដើរកណ្តាល ហើយនារីទីពីរដើរភ្ជង់កាំភ្លើងពីក្រោមថាសតាមក្រោយ ដោយពុំមានភ្ញៀវណាម្នាក់ចាប់សង្ស័យមកលើព្រឹត្តិការណ៍កណ្តាលបារនេះបន្តិចឡើយ ។

ពួកនារីនាំមិត្តយើងមកដល់ច្រកចង្អៀត ដែលមានតែពន្លឺភ្លើងពណ៌ខៀវមួយជះព្រាងៗពីក្នុងជញ្ជាំងមក តែដោយចក្ខុទាំងពីររបស់គេធ្លាប់មានការពិសោធន៍ក្នុងទីងងឹត ទើបគេអាចសម្លឹងទម្លុះឃើញអ្វីៗ នៅក្នុងទីនោះទាំងអស់គ្មានសល់ ។

ដើរបានប្រមាណជាបីជំហានទៀត នារីខាងមុខក៏ទុចជំហានហើយបែរមុខមកកាន់មិត្តយើងយ៉ាងរហ័ស ÷



-ឈប់ឱ្យស្ងៀមត្រង់ហ្នឹងសិនហើយ !

មិត្តយើងសម្លឹងទៅដៃស្តាំ ដែលនារីទើបតែដកចេញពីក្រោមថាស នោះ ក៏ឃើញមានកាំភ្លើងដៃធុនស្វ័យប្រវត្តិយ៉ាងខ្មៅស្រិល ។ ខណៈនោះនារីនៅពីក្រោយខ្នង ក៏លូកដៃទៅសង្កត់គន្លឹះយន្តនៅលើជញ្ជាំង ហើយស្រាប់តែទ្វាររបើកសន្សឹមៗឡើង លេចទាំងមនុស្សប្រុសពីរនាក់មាឌមាំៗ ពាក់មួកបាំងមុខដើរចេញមកចាប់ដៃមិត្តយើងម្ខាងម្នាក់អូសចូលទៅ ដោយមិត្តយើងបានបណ្តោយឱ្យពួកនេះមួយខ្យល់ តាមចិត្តចង់ ។ ទ្វារបិទវិញគ្រិប បំបាំងរូបនារីទាំងពីរបាត់ស្រមោល ហើយស្រាប់តែនៅចំពីមុខ លេចមនុស្សបួននាក់អង្គុយជុំវិញតុមួយធ្វើព្រងើយទៅវិញ ។ ប៉ុន្តែដោយពន្លឺភ្លើងជះខ្សោយពេក ទើបលោកកិត្តិគុណមិនអាចសង្កេតភិនភាគ អ្នកទាំងបួននោះឱ្យបានច្បាស់ ។ គេអូសមិត្តយើងមកដល់ចំពីមុខតុនៃជនទាំងបួន ហើយបុរសម្នាក់បន្លឺសម្លេងឡើង ÷

-មនុស្សឈ្មោះកិត្តិគុណ ដែលគេសង្ស័យនោះចូលមកដល់ហើយ។

ជនមួយរូបក្នុងចំណោមអ្នកអង្គុយជុំវិញតុនោះ ងើបមុខឡើងសម្លឹងមកមិត្តយើងយ៉ាងយូរ ទើបបង្ហើរសម្លេងមួយៗថា ÷

-អ្នកឯងឈ្មោះកិត្តិគុណមែនឬ ?

មិត្តយើងខំផ្ទៀងស្តាប់សព្ទសម្លេងជននោះបន្តិច ទើបតប ÷

-ចុះឈ្មោះយើងកិត្តិគុណហ្នឹង វាមានកំហុសអីនៅក្នុងបារនេះ ទើបពួកអ្នកឯងប្រើការគម្រាមកំហែង មកលើយើងខ្លាំងម្ល៉េះ ?

យើងជាភ្ញៀវមួយរូប ដូចអ្នកឯងទៀតដែរតើ ! យើងមានដែលមកស៊ីផឹកខ្វះលុយពីអង្កាល់ ?

ជននោះសើចខ្ទររពេញបន្ទប់ ÷

-ហាំៗ ! ហាំៗ ! ចំពោះលោកក្នុងឋានៈជាភ្ញៀវធម្មតា វាគ្មានកំហុសមែន ប៉ុន្តែពួកយើងបានទទួលបញ្ជាពីលោកថៅកែធំក្រុមក្ងូឡាបស ថាលោកឈ្មោះកិត្តិគុណនេះ ជាអ្នកធ្វើការនៅក្នុងក្រសួងសម្ងាត់ ដូច្នេះសូមលោកនិយាយឱ្យត្រង់មកមើល តើលោកមកនេះដើម្បី តាមដានក្រុមក្ងូឡាប-ស ពិតមែនទេ ?

-យើងមិនយល់ថា អ្នកឯងចង់និយាយដូចម្ដេចផង ហើយនិងបារក្ងូឡាបសនេះ មានអាថ៌កំបាំងយ៉ាងណាក៏យើងមិនបានដឹងដែរ ដោយយើងគ្រាន់តែជាភ្ញៀវមកផឹកកំសាន្តលេងធម្មតាប៉ុណ្ណោះ.......

-តែគេយកការណ៍បានច្បាស់ណាស់ ថាលោកពិតជាអ្នកធ្វើការតាមដានក្ងូឡាបសគ្មានច្រឡំឡើយ ដូច្នេះត្រូវតែលោកឆ្លើយឱ្យត្រង់មក បើលោកនៅតែកុហកទៀត ខ្ញុំនេះជាមច្ចុរាជដែលគេបានបញ្ជូនមកកាត់ទោសជីវិតលោក ក្នុងពេលនេះហើយ !

មិត្តយើងញោចស្នាបន្តិច មុខនៅតែញញឹម ភ្នែកទាំងគូបញ្ចាំងរស្មីដូចពេជ្រទាំងគ្រាប់ បេះដូងនឹងថ្កល់គ្មានញាប់ញ័រ តែសរសៃឈាមក្លាហានបានស្ទុះច្រាលសព្វសព៌ាង្គកាយ ។

-តែបើអ្នកឯងនិយាយដូច្នេះ សឱ្យដឹងថាពួកអ្នកឯងនេះជាឧក្រិដ្ឋជន ដែលមានធ្វើការអាថ៌កំបាំង ប្រឆាំងនឹងច្បាប់សម្រាប់រដ្ឋមែនទេ? ហើយបើដូច្នោះមែន យើងក៏គ្មានព្រីនឹងប្រាប់ពួកឯងឱ្យដឹងថាយើងជា



អ្នកតាមដានពួកឯងដែរ !

បញ្ចប់ប្រយោគសឹងមិនទាន់ មិត្តកិត្តិគុណយើងរលាស់ដៃចេញពីជនទាំងពីរយ៉ាងរហ័ស ហើយក៏លើកជើងស្ដាំវាត់ឡើងចំបំពង់កអាម្នាក់ឡើងពិប ! បណ្ដាលឱ្យអានោះប្រកាច់ទ្រេតទៅក្រោយទាំងជំហររួចបញ្ជូនដៃស្ដាំកាប់ពិបចំកញ្ចឹងកទៀត ដងខ្លួនអានោះក៏រលំក្ដូងផ្កាប់មុខលើឥដ្ឋពណ៌លែងកំរើកខ្លួនតែម្ដង ។ អាម្នាក់ទៀតហក់វឹងមកពីក្រោយ ដោយប្រាថ្នានឹងចាក់មិត្តយើងមិនឱ្យដឹងខ្លួន ប៉ុន្តែលោកអធិការពិសេសយើងមានត្រចៀកវៃដូចបក្សា កាយវិការរហ័សរហួនដូចផ្លេកបន្ទោរ ភ្លិបភ្លែតដូចអំពិលអំពែក ធ្លាប់ជ្រែកក្នុងហ្វូងជនពាលរាប់រយពាន់ផង ប្រឡងបានឈ្មោះជាអ្នកប្រយុទ្ធដៃដង្កាប់ ចាប់ដែករលាយ ភ្នំរលើង ផែនដីក្រឡាប់ មហាមេឃញ័ររញ្ជួយ គ្មានព្រួយនឹងដើរឆ្លងកាត់ខ្សាច់ក្ដៅ ហែលកាត់សមុទ្រភ្លើងទៅផុតជើងមេឃសោះឡើយ ហើយក្នុងពេលចុងកាំបិតសត្រូវចាំងភ្លែតពីក្រោយមកជិតដល់សាច់ហើយនោះ លោកកិត្តិគុណយើងបន្ទន់ខ្លួនបន្តិច រួចវាត់ដៃទៅក្រោយចាប់កដៃវាជាប់ ហើយបោកភឹងមកខាងមុខតាមស្នៀតយូដូអន្តរជាតិ ដែលលោកធ្លាប់បានហាត់រៀនយ៉ាងស្ទាត់ជំនាញនោះ អាចកាច់ទម្ងន់មនុស្សរាប់រយគីឡូ ឱ្យទៅជាស្រាលដូចសំឡីបាន ។ សត្រូវធ្លាក់ដល់ឥដ្ឋលាន់ឌឹប ! រមៀលខ្លួនបីប្អូនត្រឡប់ តែដោយវាមានទេពកោសល្យខាងយូដូ បន្ទន់ខ្លួនគ្រាន់បើដែរ ទើបមិនអាចធ្វើឱ្យវាបាក់បែកឆ្អឹង ។ អានោះស្ទុះក្រោកភ្លែត ហក់វឹងមករកសង្គ្រប់មិត្តយើងដូចក្របីឡើងក ទាំងបញ្ចេញមុខសាហាវគួរឱ្យខ្លាច តែកិត្តិ

គុណបានបង្វិលខ្លួនគេចផុតមុន បណ្ដាលឱ្យដងខ្លួនអានោះជ្រុលឆ្ពោទៅផ្ទប់នឹងជញ្ជាំង ទាំងបុកកាំបិតកប់លិចបាត់ជិតពាក់កណ្ដាលដងផង ហើយរហ័សដូចផ្លេកបន្ទោរ បុរសពិសេសដៃដែកយើងហក់ទៅពីក្រោយ ដោយវាត់កែងដៃបញ្ជូនចំកញ្ចឹងក លាន់ផស ! រួចកាប់បន្ថែមប៉ុន្មានដៃទៀត ដងខ្លួនអានោះក៏រលំគ្រេងលែងកំរើកតែម្ដង ។

មិត្តកិត្តិគុណយើង ងាកភ្នែតមករកជនទាំងបួន ដែលក្រោកឈរពីកៅអីឈរសម្លឹងមកគេផ្ទាំង ដូចសត្វខ្លាកំពុងប្រុងលោតសង្គ្រប់ម្រឹគ។

-នៅឱ្យស្ងៀម ! បញ្ចេញក្បាច់ប៉ុណ្ណឹងបានហើយ ! បើមិនស្ដាប់គ្រាប់កាំភ្លើងយើងមិនចេះយោគយល់ទេវើយ !

ជនទីមួយឈរភ្ជង់កាំភ្លើងមក ដោយសម្លេងដាច់អហង្ការ ។

លោកកិត្តិគុណ ទុចជំហាន បើកភ្នែកធំៗ សម្លក់ទៅម្ចាស់សម្លេង ÷

-ពួកឯងជាចោរក្រុមក្ងូឡាបសមែនទេ ?

-បើដឹងហើយមិនគួរសួរទៀតទេ លោកកិត្តិគុណ !

-តែពួកឯងមានបំណងយ៉ាងណាខ្លះ មកល្បើរួបយើង ទើបបានពួកឯងហ៊ានដាក់អន្ទាក់អ្នកមានពិសយ៉ាងនេះ ? មិត្តយើងសួរដោយគ្មានតក់ស្លុតបន្តិច ចំពោះចុងកាំភ្លើងនិងបច្ចាមិត្តមាឌធំៗទាំងបួន ។

-ពួកយើងដឹងថា លោកជាពស់មានពិស ទើបខំធ្វើការកំចាត់លោកចោលក្នុងពេលនេះ ព្រោះពិសលោក អាចធ្វើឱ្យខូចនូវគំរោងការធំៗ របស់ក្រុមយើង !

-ចុះបើកំចាត់មិនបានវិញ ? មិត្តយើងគំហកតប



ជននោះឈានមកមុខមួយជំហាន ÷

-គ្រាប់កាំភ្លើងតែងសំរេចនូវ គោលបំណងគ្រប់យ៉ាងនៃក្រុមយើង!

-ហើយយើង........ ក៏.........

ប៉ុង ! អូយ........ អាំ.....

បន្ទាប់ពីសូរគ្រាប់កាំភ្លើងមួយប៉ុង សម្លេងមនុស្សម្នាក់ដង្ហោយស្នើរកប់អាកាស ហើយរហ័សដូចខ្លា មិត្តយើងដែលមានទឹកដៃក្នុងការប្រើកាំភ្លើងខ្លី រកមើលមិនទាន់បានលោតគេចទៅម្ខាងវិញ ប្រហែលបួនព្យាមទាំងដៃស្ដាំគេ លើកកាំភ្លើងភ្ជង់ទៅរកសត្រូវបីនាក់ទៀតជាស្រេចដែលកំពុងតែឈរឡើងឡង់ភាំងស្មារតី ចំពោះកាយវិការដ៏សែនរហ័សនៃមិត្តយើង ។

មិត្តកិត្តិគុណឈរបង់ជំទែងយ៉ាងអង់អាច កាំភ្លើងនៅដៃនឹងថ្កល់គ្មានងាករេបន្តិច ហើយភ្នែកទាំងគូបានជះរស្មីទៅលើបច្ចាមិត្តទល់មុខទាំងបីគួរឱ្យព្រឺ ។

-បើស្គាល់យើងជានរណាហើយ ត្រូវកុំកំរើកខ្លួន ហើយលើកដៃឡើងលើក្បាល !

ជនទាំងបីដៃទទេ មិនហ៊ានរឹងទទឹងទៀត ក៏លើកដៃឡើងលើព្រមគ្នា ហើយខណៈនោះមានស្រមោលមនុស្សម្នាក់លបសន្សឹមៗ មកពីក្រោយមិត្តយើងដោយមានកាន់ដបមួយយារឡើង ប្រុងសំពងក្បាលជាស្រេចផង ។ ដបធ្លាក់រួចំក្បាល គួរឱ្យស្លុតស្នើរផុតដង្ហើម តែដោយមិត្តយើងសង្កេតទឹកមុខបច្ចាមិត្តទាំងបីពីមុខយល់បានមុន ក៏ផ្ដេកខ្លួនភ្វេត ប៉ុន្តែយឺតបន្តិចទៅហើយ ដបជ្រួសមកចំដៃកាន់កាំភ្លើង ដូចជា

វាយទំលាក់ពីដៃ បណ្ដាលឱ្យមិត្តយើងស្រយង់ដូចត្រូវចាក់ឆ្អឹង ។ មិត្តជាអ្នកមានបេះដូងស្រោបដែក វិញ្ញាណរចនាដោយទឹកមន្តព្រះព្រហ្ម មិត្តកិត្តិគុណយើងបង្វិលខ្លួនតាមស្នៀតប្រដាល់ខ្មែរ បុកជង្គង់បញ្ច្រាស់ចំកណ្ដាលទ្រូងអានោះប៉ើងទៅក្រោយ ហើយមិនបណ្ដាក់ឱ្យយូរការលោកអធិការដ៏ក្លាហានរបស់យើង វាត់មួយជើងបញ្ជូនទៅចំកណ្ដាលមុខវាទៀត លាន់ផាំង ! លោហិតក៏ហូរភលៗពីមាត់និងច្រមុះ រួចដងខ្លួនវាក៏រលំត្បោលជាបន្ទាន់ ។ គ្រាន់តែមិត្តយើងទប់ជំហរ ហក់មកក្រោយមួយជំហាន ជនទាំងបីបានឱកាសក៏ហក់ស្រចូលមកព្រមគ្នា ដើម្បីព្រួតវាយកំទេចមិត្តយើងកុំឱ្យសំរាកយកកម្លាំងទាន់ ។ ឆាកប្រយុទ្ធផ្ទាល់ខ្លួនដោយដៃទទេ ក៏បានបើកឡើងដោយម្នាក់ទល់នឹងបី។ យើងឮសូរតែព្រួសប្រាស។ ក្នុងក្ដាំងពេញទាំងបន្ទប់ មិនអាចស្មង់ដឹងថា មិត្តយើងម្នាក់ឯងអាចទប់ទល់ជាមួយសត្រូវទាំងបីបាន ឬមិនបាននោះឡើយ ។ ខ្ញុំសូមជំរាបថា លោកអធិការកិត្តិគុណមានដើមកំណើតនៅឯខេត្តបាត់ដំបង លោកធ្លាប់បានហាត់រៀនស្នៀតប្រដាល់ខ្មែរយ៉ាងស្ទាត់ ហើយដល់មកបានចូលកាន់តំណែងជាអធិការ លោកបានបំពេញក្បាច់យូដូ និងអ្វីៗពិសេសជាច្រើនទៀត ក្នុងរឿងប្រយុទ្ធតានដាន ក្លែងខ្លួនផ្លាស់ប្ដូរជីវភាពពីមួយទៅមួយ ដោយគ្មានទើសនៅក្នុងក្រសួងសន្តិសុខជាតិយើង ហើយជាពិសេសណាស់ទៀត គេបានប្រោកដនាមជូនលោកថា អធិការពិសេសដៃដែកភ្នែកទិព្វ ។

មួយសន្ទុះប៉ុណ្ណោះ យើងឃើញជនម្នាក់វិលខ្វាល់ ដោយត្រូវនឹងទំហំជើង លោកកិត្តិគុណប្រកាច់តតេះតតះ ទៅដួលស្រពាប់បាត់មាត់



ទៅកៀនជញ្ជាំង ហើយចំណែកមិត្តដ៏ក្លាហានរបស់យើងវិញ អាវត្រូវរហែកដូចច្រៀកជៀត មុខជាំមួយដុំពីរ តែពុំជាធ្ងន់ធ្ងរណាស់ណាទេ គេអាចនៅមានកម្លាំងកំហែងប្រយុទ្ធបានដដែល ។ មិត្តយើងទប់សន្ទុះដៃសត្រូវ រួចហក់ដកឃ្លាចម្ងាយមួយម៉ែត្រទៅក្រោយ ដើម្បីប្រមូលយកស្ថានភាពប្រយុទ្ធថ្មី ។ ពេលនោះជនម្នាក់ ហក់ភ្លែតទៅស្រវាបើសកាំភ្លើង ដែលមិត្តយើងធ្វើឱ្យជ្រុះអម្បាញមិញនោះ តែវាពុំអាចសម្រេចបំណងបានឡើយ ដោយមិត្តយើងយល់ដឹងការទាន់ ក៏លោតទៅជាន់ដៃអានោះជាប់ ហើយលើកបាតដៃដែកកាប់យ៉ាងអស់ទំហឹង ផាំង ! ផាំង ! ផ្ទួនគ្នាលើកញ្ចឹងក រួចលើកចុងស្បែកជើងឈូសបញ្ច្រាស់កណ្ដាលមុខវាបន្ថែមទៀត បណ្ដាលឱ្យអានោះលាន់មាត់ស្រែកអូយមួយម៉ាត់ ក៏ផ្ងារស្រទាងទៅក្រោយទាំងឈាមរហាម។ ឃើញដូច្នោះអាម្នាក់ទៀត ក៏ដកខ្លួនរកមាត់ទ្វារ តែមិត្តយើងរហ័សដូចផ្លេកបន្ទោរ លោតទៅក្របួចកអាវវាពីក្រោយជាប់ ហើយក៏ព្រលែងកណ្ដាលមុខឆ្អឹងជំនីរបីបួនដៃជាប់គ្នារដឹក រួចអូសវាត្រឡប់មកកណ្ដាលបន្ទប់វិញ ។ ត្រូវប៉ុណ្ណឹងហើយវាមិនទាន់អន់ មិត្តយើងវាយគប់ បុកពោះ រុញត្រឡប់ទៅដល់អាងទឹក រួចចាប់ក្បាលវាជ្រមុជទឹកបីបួនផង ទាល់តែអានោះទ្រាំលែងបានទៀត......... ។

-លោកអើយ........ ខ្ញុំរាងហើយ....... ឈប់ធ្វើបាបខ្ញុំទៅ,......ខ្ញុំខ្លាចលោកហើយ,........

មិត្តយើងដាក់វាអង្គុយលើមាត់អាងទឹក ព្រមទាំងសួរដោយសង្កត់ពាក្យធ្ងន់ៗ ÷

-អ្នកណាជាមេក្រុមក្លូឡាបស ? ឆ្លើយប្រាប់យើងមក ទើបយើងឈប់ធ្វើបាប ។

នាយនោះគ្រវីក្បាល រលាសទឹក ទាំងតបខ្សាវៗ ÷

-ខ្ញុំមិនបានស្គាល់ទេលោក......... ខ្ញុំមិនស្គាល់សោះ....... មិនដឹងជានរណា ហើយនៅឯណាទេលោក...... សូមលោកជឿខ្ញុំចុះ......។

-បើគាត់ឯងមិនស្គាល់មេនោះ តើអ្នកណាបញ្ជាគាត់ឯងមកសម្លាប់យើង ?

-ខ្ញុំ....... ខ្ញុំមិនបានស្គាល់គេទាល់តែសោះ គឺបញ្ជាទាំងនោះចេញមកដោយសម្ងាត់ ពីមនុស្សប្រចាំក្រុមម្នាក់នៅក្នុងក្រុងនេះ........ ។

-មនុស្សម្នាក់នោះឈ្មោះអី នៅឯណា ?

-គេចេញបញ្ជាភ្ញីបភ្នែកដូចអំពិលអំពែក ចួនបាត់ឈឹង ចួនចេញមកក្រឡឹម ប៉ុន្តែមិនអាចស្គាល់មុខទាល់តែសោះ ព្រោះគេបញ្ចេញខ្លួនមិនខុសពីស្រមោលឡើយ សូមលោកមេត្តាទៅចុះ....... ខ្ញុំដឹងថាជិតស្លាប់ហើយ ហើយបើខ្ញុំបានដឹងបានស្គាល់ ច្បាស់ជាខ្ញុំមិនលាក់នឹងលោកទេ....... លោក......... ។

-គាត់ឯងដឹងខ្លួនថាជិតស្លាប់ ? អ្នកណាមកសម្លាប់គាត់ឯង បើមានយើងនៅទីនេះហើយ ?

-បាទ..... លោក......... មិនកំបាំងពីភ្នែកពួកអាថ៌កំបាំងក្លូឡាបសទេ....... គេ...... នៅជិតបង្កើយអស់ហ្នឹង....... ប៉ុន្តែ........ គេមិនទាន់ចេញមុខមក..........

មិត្តយើងរវេភ្នែកជុំវិញខ្លួនយ៉ាងយកចិត្តទុកដាក់ ហើយប្រុងប្រយ័ត្ន



ស្មារតីជាថ្មីដើម្បីចាំទប់ទល់ ជាមួយមនុស្សក្លូឡាបសអាថ៌កំបាំង ប៉ុន្តែនៅជុំវិញទីនោះពុំមានអ្វីគួរឱ្យសង្ស័យសោះ ទើបមិត្តយើងបន្ធូរខ្យល់បន្តិច ហើយបោះសំនួរថែមទៀត ÷

-នៅក្នុងបារនេះមានបក្សក្លូឡាបស មកបន្ទំធ្វើការប៉ុន្មាននាក់ ?

-បាទ...... មានខ្លះដែរ.......... ចំនួន

ចុប! កាំបិតមួយហើរជ្រែកមហន្តការ មិនដឹងពីទីណាមកទម្លាយបំពង់កនាយនោះ បណ្ដាលឱ្យប្រកាច់ធ្លាក់ពីមាត់អាងទៅក្នុងទឹកអណ្ដែតស្ដឹង លែងបានបញ្ចប់ចម្លើយ ។ លោកកិត្តិគុណដឹងថាសត្រូវនៅមានក្បែរខ្លួននៅឡើយ ក៏ប្រះខ្លួនភឹងស្រវាចាប់កាំភ្លើងមកកាន់យ៉ាងរហ័ស ហើយក៏ប្រមៀលខ្លួនទៅរកមាត់ទ្វារដែលនៅចំហរស្រាប់។ មិត្តយើងស្ទុះក្រោកឈរអែបនឹងជញ្ជាំង លួចសម្លឹងទៅក្នុងបន្ទប់វិញដើម្បីរកមើលឃាតករបំបាត់ដាន ប៉ុន្តែពុំមានស្រមោលអ្វីគួរឱ្យចាប់មន្ទិល ថាមានមនុស្សនៅពួនជិតៗនោះសោះឡើយ ហើយស្រាប់តែខណៈនោះ មានស្នូរអ្វីលាន់ក្រឹត រួចក៏បាត់ពបឹងទៅវិញ បណ្ដាលឱ្យមិត្តយើងយល់បានថា ឃាតករពួននៅក្នុងបន្ទប់ម្ខាងទៀត ហើយថែមទាំងបានប្រើទ្វារពិសេសសម្រាប់គប់កាំបិត ប្រហារមនុស្សបំបាត់គាងទៀតផង ។ រំពេចនោះស្នូរជើងមនុស្ស រត់ពីក្រោយមកយ៉ាងសន្ធឹក យ៉ាងហោចក៏ជាងដប់នាក់ដែរ ទើបមិត្តយើងដែលកំពុងតែនពួលភាពស្រាប់ មានការចាំបាច់ត្រូវតែដកឃ្លាមួយគ្រាសិន ។

ងាកមករកទ្វារចេញស្រាប់តែគេបិទជិតឈឹងមិនដឹងតាំងពីអង្កាល់ ហើយភ្លើងក៏ពន្លត់ងងឹតសូន្យទៀត អាសន្នធំមកដល់ហើយ ! ស្នូរ

ជើងមនុស្សក៏កាន់តែជិតមក មិត្តយើងងាកនាយអាយក៏ឃើញមានបន្ទប់មួយចំហរបង្អួច ក៏ហក់ចូលទៅក្នុងនោះប្រូចបាត់ភ្លាម ហើយមនុស្សប្រមាណដប់នាក់ សុទ្ធតែមានកាន់កាំបិតខ្វីនៅដៃ បានរត់មកដល់ល្មម ។ វានាំគ្នារុករើពាសពេញក្នុងបារ ក្រោមតុ ក្នុងទូ ក្នុងឡាំង ក្នុងរាំងននអស់មួយសន្ទុះ ក៏លើកគ្នាត្រឡប់ទៅក្រោយវិញអស់ទៅ ។ នៅខាងក្នុងបន្ទប់មិត្តយើងអោបរាងកាយនារីម្នាក់ នៅលើគ្រែដ៏មានសាច់ត្រជាក់ស្រិបដូចទឹកកក ដើម្បីពួនសម្ងំយករួចខ្លួន ប៉ុន្តែ តាំងពីលោកក្រសោបអោបជាប់រហូតមកដល់ឥឡូវ លោកពុំឃើញនារីនោះមានប្រតិកម្មអ្វីបន្តិចសោះ ហើយសាច់សោតក៏កាន់តែត្រជាក់ឡើងៗ ដូចជាពុំមានចំហាយក្ដៅរបស់មនុស្សមានជីវិតបន្តិចសោះ បណ្ដាលឱ្យលោកអធិការយើងព្រឺខ្លួន ព្រឺក្បាលសំពោង ហើយក៏ប្រញាប់បង្វិលខ្លួនចុះពីគ្រែភ្លាម ។ ដោយមិនអស់ចិត្ត លោកកិត្តិគុណលូកដៃស្រាលៗទៅស្ទាបដង្ហើម.........

-ពុទ្ធោ ! ....... នាងស្រីនេះស្លាប់ទេតើ........ អីចឹងបានជាសាច់ត្រជាក់ហើយដងខ្លួនរឹងស្ដូក អោបជិតកន្លះម៉ោងហើយនៅតែមិនដឹងខ្លួនដដែល.......

លោកកំឡោះលាន់មាត់តែម្នាក់ឯង ហើយហៀបនឹងឈានជើងទៅរកបើកភ្លើងមើលមុខទៅហើយ ស្រាប់តែមានមនុស្សមួលសោទ្វារបន្ទប់ពីក្រៅក្រិកៗ! មិត្តយើងរកកន្លែងលាក់ខ្លួនមិនទាន់ ក៏លូនចូលទៅពួនក្រោមគ្រែដើម្បីចាំសង្កេត តើអ្នកណាចូលមកកាន់បន្ទប់ឃាតកម្មនេះ ? ទ្វាររបើកតិចៗ ជើងមនុស្សបីនាក់បោះជំហានចូលមក



យ៉ាងស្វាហាប់ ដោយជននាំមុខ មានកាន់ពិលតូចមួយប៉ុនមេដៃបញ្ចេញពន្លឺព្រិលៗដូចអំពិលអំពែក តែពន្លឺភ្លើងពិលដ៏ទន់ខ្សោយនោះក៏អាចជះមកក្រោម ឱ្យមិត្តយើងឃើញជនរាត្រីទាំងបីនេះច្បាស់ណាស់ដែរ ។ ជនកាន់ពិលពាក់ស្បែកជើងខ្មៅចងខ្សែ តែខ្សែខាងស្ដាំមានតំណរមួយល្មមឱ្យកត់សំគាល់ចំណាំបាន ឯជនពីរនាក់ទៀតសុទ្ធតែជើងទទេ ប៉ុន្តែជនទីបីមានកំបុតកូនជើងខាងស្ដាំមួយដែរ មិត្តយើងកត់ចំណាំទុកក្នុងចិត្ត ហើយចាំស្ដាប់ការសន្ទនារបស់ឧក្រិដ្ឋជនទាំងនោះ ។

-នាងនេះបានប្រព្រឹត្តខុសវិន័យ ទើបត្រូវគេប្រហារជីវិតនាង (ជនទីមួយពោល) ហើយឥឡូវគេឱ្យយើងយកទៅកប់ចោលនៅជើងភ្នំខាងក្រោយ ដើម្បីកុំឱ្យអ្នកនៅក្នុងបារទាំងប៉ុន្មានដឹងទាន់.........

-កំហុសនាងដូចជាស្រាលទេ មិនគួរមានទោសដល់ថ្នាក់ហ្នឹងសោះ ម្ដេចក៏មានបញ្ជាឱ្យសម្លាប់នាងទាន់ហន់ម្ល៉េះ ? ជនទីពីរនិយាយថ្នមៗ ។

-ប៉ុន្តែនាងបានធ្វើឱ្យបាត់សំបុត្រតូចមួយ ដែលមានហត្ថលេខាលោកថៅកែធំក្រុមក្លូឡាបសនៅឯភ្នំពេញ ដែលអ្នកស្រីថាវីបានផ្ញើឱ្យទុកពីល្ងាចមិញ........

-សំបុត្រនោះ ធ្លាក់ទៅក្នុងដៃក្រសួងមានសមត្ថកិច្ច ច្បាស់ត្រូវរលើងទាំងឫសទាំងគល់គ្មានសល់មួយទេ ព្រោះតែយ៉ាងហ្នឹងហើយទើបមានបញ្ជាថាឱ្យសម្លាប់នាងចោលជាបន្ទាន់ ។

-ឥឡូវសំបុត្រនោះរកឃើញវិញហើយឬនៅ ?

-កៀបសួរអស់ចិត្តទៅ នាងថាមិនឃើញសំបុត្រនោះទេ កាលដែលអ្នកស្រីថាវីរផ្ញើនោះ គឺបារីមួយកញ្ចប់មែន ត្រង់ឯសំបុត្រនោះនាងមិនបានឃើញទាល់តែសោះ........

-ហើយបើនាងបានឃើញតែបារីមែន ធ្វើម្តេចឱ្យនាងឆ្លើយថាឃើញសំបុត្រកើត ?

-ពិបាកណាស់ ! អ្នកស្រីគាត់ថាសំបុត្រនោះបានញាត់ទៅក្នុងកញ្ចប់បារី តែអ្នកស្រីមិនបានប្រាប់ការពិត ព្រោះខ្លាចក្រែងបែកការ។ ដល់គាត់ត្រឡប់មកពីកោះវិញ ស្រាប់តែឃើញនាងហ្នឹងអង្គុយរួមតុជាមួយមនុស្សដែលកំពុងតែសង្ស័យ ហើយគាត់ហៅនាងនោះឱ្យទៅជួបសួរយកកញ្ចប់បារីវិញ តែនាងនោះបានឆ្លើយថា បារីមួយកញ្ចប់នោះនាងបានប្រគល់ឱ្យបុរសស្នេហ៍ទៅហើយ ដោយនាងពុំបានដឹងថាមានអាថ៌កំបាំងអ្វីនៅក្នុងនោះសោះឡើយ ។

-ចុះបុរសស្នេហ៍របស់នាងធ្វើអ្វី ? ផ្ទះនៅដល់ណាទៅ ?

-ពួកយើងបានហៅវាចូលទៅក្នុង បំរុងនឹងឆែកឆេរ តែត្រូវវានោះបញ្ជូនទៅស្រុកខ្មោចគ្មានសល់ម្នាក់ទេ........ វានោះមានថ្វីដៃដូចហនុមាន.......

-ឈ្មោះអី ?

-ឈ្មោះកិត្តិគុណ បើតាមអ្នកយកការរបស់យើងបញ្ជូនមក.......

-ធ្វើការអីដែរ ?

-មិនទាន់ច្បាស់នៅឡើយ តែបុរសកិត្តិគុណនោះបានមកកាន់ក្រុងនេះក្នុងឋានៈជាអ្នកដើរកំសាន្តធម្មតា...... (ជនទីមួយកាន់ពិលតប)



-បើអីចឹងខ្ញុំហ៊ានសន្និដ្ឋានថា សំបុត្រនោះពិតជានៅកញ្ចប់បារីនៅឡើយទេ ហើយជនដែលឈ្មោះកិត្តិគុណនោះ ក៏ពិតជាពុំបានចាប់ភ្លឹកក្នុងរឿងដ៏អាថ៌កំបាំងនេះដែរ.........

-តែបើប្រសិនបានឃើញសំបុត្រនោះ ក៏មិនអាចមើលយល់ដាច់ខាត ព្រោះជននោះពុំមានទាក់ទងជាមួយក្រុមក្លូឡាបស......

-រឿងនេះមិនបាច់យើងវែកញែកអ្វីទេ ព្រោះស្រីនេះក៏ស្លាប់ ឯសំបុត្រក៏បង់ទៅទៀត ហើយឯកិច្ចការផ្សេងៗយើងប្រុងតែចាំធ្វើតាមបញ្ជាគេទៅ !

ជនទីពីរនិងទីបី ដើរមកឈរចុងជើងគ្រែ ហើយឮជនទីមួយនិយាយទៀត ÷

-នាងស្ងួភីនេះ ជាតារានៅក្នុងបារនេះ ឯការធ្វើឃាតកម្មលើរូបនាង គឺមិនមែនបាត់ចែងដោយអ្នកនៅក្នុងទីនេះទេ.......

-អ្នកណាលូកដៃមកក្នុងឃាតកម្មនេះខ្លះ ? ជនទីបីសួរបញ្ជាក់

-គឺជាក្រុមក្លូឡាបសនៅឯកោះពស់ ពួកនោះមានថ្វីដៃធ្វើការអាថ៌កំបាំងបានសម្រេច ជាច្រើនដងរួចមកហើយ ជាពិសេសពីព្រលប់នេះ មានភ្នាក់ងារក្រុមព្រះនគរបាលម្នាក់លបឆ្លងទៅលើកោះ ហើយត្រូវពួកនោះចាប់បានទុកឱ្យស៊ីថ្នាំទំរាំដល់ពេលស្លាប់ ។

ប្រយោគនេះបានកន្ត្រាក់ដួងវិញ្ញាណ មិត្តយើងដែលសម្ងំនៅក្រោមគ្រែ ឱ្យញ័ររញ្ជួយស្ទើរតែទប់សម្ងំតទៅទៀតលែងបាន ប៉ុន្តែបេសកកម្មដ៏ធំ ធំលើសព្រះសុមេរុ លើសទ្វីបលោក លើសមហាមេឃបានចាប់ទាញសន្ទុះចិត្តលោកឱ្យនោរទន់បន្តិចវិញ កុំអីប្រហែល

ជាលោតហក់ចេញមកបាញ់បំបែកលលាដ៍ក្បាល ពួកវានេះឱ្យវិនាស តែហោងជាស្រេច ។ នាងសូភីត្រូវស្លាប់ដោយដៃមនុស្សឃោរឃៅ កញ្ចប់បារីដែលលោកបានទទួលពីនាង មិនដឹងជាញីបោះចោលនៅកន្លែងណា ហើយសហការីលោកបានធ្លាក់ ក្នុងអន្ទាក់សត្រូវនៅលើកោះពស់ទៀត ។ លោកអធិការកិត្តិគុណ ទើបតែឈានជើងមកដល់ក្រុងនេះម្ដង មិនដឹងជាកោះពស់នោះនៅឯណានៅឡើយផង ហើយជាពិសេសបើលោកធ្វើឱ្យមានប្រតិកម្មខ្លាំងក្លាក្នុងរាត្រីនេះ ត្រីរស់ក័ររួចទន្សាយក័ររួច បានសេចក្ដីថា ពួកចោរប្លន់ជាន់ឈ្លីសេដ្ឋកិច្ចក៏បាត់របស់មានតំលៃជាច្រើនទៀត ដែលកំពុងតែកប់ងងឹតសូន្យសុងនោះនឹងវិនាសអន្តរាយបាត់ស្រមោលជាមិនខាន ។ ម៉្លោះហើយលោកអធិការនៃក្រសួងមានសមត្ថកិច្ចយើង ត្រូវឈានដើរសន្សឹមៗទៅរកគោលដៅជ័យជំនះរហូតអវសាន ។

លោកខំផ្ទៀងស្ដាប់ទៀត តែពេលនោះសត្រូវទាំងបីបានដើរក្រឡឹងជុំវិញគ្រែ ហើយនាយម្នាក់ពោលថា ÷

-បាត់ការទៅ ! នៅខាងក្រៅស្ងាត់ស្រួលហើយ......

ចប់ប្រយោគនេះជនទាំងបី ក៏បោះជំហានចេញពីបន្ទប់ទៅយ៉ាងលឿន ដោយបានលីទាំងរូបនាងសូភី នារីអភ័ព្វទៅជាមួយផង ។ មិត្តយើងស្ទុះចេញភ្លែតពីក្រោមគ្រែ ហើយលបតាមមើលដំណើរពួកវា រហូតដល់ទ្វារក្រោយ ទើបប្រញាប់ត្រឡប់មកវិញហើយចូលបង្ហួសទៅកាន់តុមួយ ដែលមានដំកល់ទូរស័ព្ទទុកសម្រាប់ប្រើការនៅទីនោះ។ លោកអធិការងាកមើលឆ្វេងស្ដាំបន្តិច ទើបលូកដៃរវៃលេខ ហើយ



លើកបំពង់ទូរស័ព្ទមកនិយាយ ÷

-អ្នកណាកាន់ទូរស័ព្ទនេះ ?

ពីខ្សែម្ខាងតបមកវិញ ÷

-ខ្ញុំអ្នកយាមទាន...... ឈ្មោះកែវ.......

-អ្ហូ ! បងកែវអ្ហា ! ខ្ញុំណាំ....... អធិការពិសេស បងស្គាល់មាត់ខ្ញុំហើយមែនទេ ?

-លោកមានការអីហ្នឹងទាន ?

-បងកែវឯងត្រូវជំរាបលោកស្នងការ ឱ្យលោកនាំគ្នាមកចាប់មនុស្សទុច្ចរិតនៅពីក្រោយបារក្លូឡាបស ក្នុងពេលនេះជាប្រញាប់ គឺមនុស្សបីនាក់កំពុងតែកប់ខ្មោចស្រី ដែលមានទាក់ទងជាមួយពួកក្លូឡាបស ហើយកុំភ្លេចជំរាបលោកថា ខ្ញុំសុខសប្បាយជាទេហ្នា ! អ្ហូ ! ខ្ញុំភ្លេចសួរបន្តិចសិន កុំអាលដាក់ទូរស័ព្ទ !

-សួរអំពីស្អីទាន ?

-កោះពស់នោះនៅឯណា បងកែវឯងស្គាល់ឬទេ ?

-បាទស្គាល់ទាន ! កោះពស់នៅចំពីមុខកំពង់ផែយើង បើលោកមើលទៅឃើញកោះណានៅជិតជាងគេ គឺកោះនោះហើយទាន......

-ចុះបងព្រិលគាត់ទៅណាហើយ ?

-ឃើញគាត់ពាក់អាវភ្លៀងមកមួយភ្លែតដែរ តែមិនដឹងជាគាត់ចេញ បាត់ទៅណាហើយទេទាន.......

-អរគុណ ! ខ្ញុំលាសិនហើយប្រញាប់ណាស់ !

អធិការដៃដែកដាក់ដៃទូរស័ព្ទចុះហើយប្រុងនឹងងាកហើយ ស្រាប់

តែមានដៃមួយលូកមកចាប់ស្មាពីក្រោយ ដោយបន្លឺសម្លេងតឹងៗ ÷

-រាត្រីសួស្តីលោកកិត្តិគុណ ! ខ្ញុំស្មានតែលោកហោះទៅណាបាត់ហើយ មិនស្មានថាបានមកជួបលោកដោយចៃដន្យក្នុងទីនេះសោះហី!

មិត្តយើងភ្ញាក់ក្រញាង ទប់ខ្លួនជាប់មិនឱ្យរំភើបពេក ហើយសួរដោយមិនបាច់ងាកមើលមុខម្ចាស់សម្លេង ÷

-អ្នកឯងជានរណាប្រាប់យើងមកមើល ?

-យើងជាមនុស្សសម្ងាត់នៅក្លូឡាបស លោកមិនបាច់ចង់ស្គាល់ឈ្មោះ ស្គាល់មុខយើងទេ ហើយបើលោកចចេស យើងចង់សម្លាប់លោកពេលណាក៏បានដែរ លោកស្តាប់បានហើយឬនៅ ?

ឮប្រយោគនេះ មិត្តយើងប្រុងងាកទៅមើលជនអាថ៌កំបាំងក្រុមក្លូឡាបស តែជននេះបានរុញចុងកាំភ្លើងមកទប់ស្មាមុនជាស្រេច ។

-សូមលោកកុំងាករឿសោះ ព្រោះលោកជាសត្វខ្លា កាលណាខ្ញុំបណ្តោយលោកទៅ លោកច្បាស់ជាបញ្ចេញចង្កូមដាក់ខ្ញុំក្នុងពេលនេះមិនខាន ឥឡូវហុចកាំភ្លើងឱ្យមក !

លោកកិត្តិគុណជាកំពូលមនុស្ស មានចិត្តក្លាហានពុះកញ្ជ្រោលជាប់ជំក្នុងលង្វែកទ្រូង ដូចភ្នំភ្លើង មានស្មារតីវាងវៃស្រួចថ្លាដូចម្ជុល អាចកាត់យល់ហេតុការណ៍ផងទាំងពួង ដោយមិនបាច់ពិចារណាច្រើន ។ ជនមិនស្គាល់មុខនេះ ពិតជាមនុស្សធ្លាប់យកការវាយប្រហារ និងការស្លាប់រស់ជាល្បែង ទើបជននេះមានវាចាណែនក្តន់គ្មានញាប់ញ័រ ហើយពុំមានឮសូរខ្យល់ដង្ហើមខ្ញីវែងខុសប្រក្រតីបន្តិចសោះ ម៉្លេះហើយលោកអធិការយើងត្រូវតែប្រយ័ត្នជាងពេល



ណាទាំងអស់ ។ ថ្វីបើកម្លាំងពលំពុំសូវបរិបូណ៌ដូចធម្មតា ប៉ុន្តែស្មាធ្លាប់រែកអម្រែកធ្ងន់ គ្មានរុញរាក្នុងនាទីជាអ្នកផ្សងព្រេង ការពារផលប្រយោជន៍ជាតិ អធិការកិត្តិគុណត្រូវតែពុះពារ ព្យុះឧបសគ្គអន្ទាក់សត្រូវក្បត់ជាតិ ក្បត់សេដ្ឋកិច្ចជាតិរហូតតំណក់លោហិតជាចុងក្រោយបង្អស់ !.....

-អ្នកឯងត្រូវការរូបយើងជាចាំបាច់ណាស់ទៅឬ ? មិត្តយើងសួរជននោះធ្វើហ៊ឺះ រួចតប ÷

-មិនជាចាំបាច់ប៉ុន្មានទេ ប៉ុន្តែក៏ខានមិនបានដែរ ! បើលោកសារភាពប្រាប់យើងតាមត្រង់ ថាលោកជាភ្នាក់ងារក្រសួងសម្ងាត់ យើងនឹងលែងលោកឱ្យរួចខ្លួនទៅវិញភ្លាម ហើយបើលោកនៅតែកុហកដដែល លោកនឹងត្រូវគេកាត់ទោសបំបាត់ដានចោលមួយរំពេច ។

មិត្តយើងធ្វើជាសើចបន្តិច ដើម្បីសំដែងចិត្តក្លាហានចំពោះមុខបច្ចាមិត្ត ÷

-យើងគ្មានទាក់ទងក្នុងរឿងអ្វីទាំងអស់ ទាំងក្នុងបារទាំងខាងក្រៅបារ គឺយើងជាភ្ញៀវធម្មតាក្នុងបារនេះតាំងពីដំបូងរៀងមក ហើយហេតុផ្សេងៗកើតឡើងក្នុងរាត្រីនេះ សុទ្ធតែជារឿងប្រឌិតរបស់ក្រុមអ្នកឯងទាំងអស់ ។

-លោកនៅតែកុហកដដែល ! ព្រោះអម្បាញមិញខ្ញុំស្តាប់ការសន្ទនាតាមទូរស័ព្ទបានទាំងអស់ មិនគឺលោកហៅស្នងការដ្ឋានទេឬ?

-ហ្នឹងហើយយើងហៅមែន ! តែហៅលោកដើម្បីឱ្យមកជួយយកយើងចេញពីបារនេះ ដែលពួកក្លូឡាបសប៉ុនប៉ងជីវិតយើងដោយគ្មាន

កំហុស.......

-បើលោកស្នងការអញ្ជើញមកកាន់ទីនេះដែរ ត្រូវតែលោកធ្វើដំណើរចេញពីនេះ ជាមួយខ្ញុំឱ្យបានមុន ទៅខាងឆ្វេង !

ជននោះរុញចុងកាំភ្លើង បញ្ជាមិត្តយើងឱ្យដើរងាកឆ្វេង ចេញតាមច្រកតូចមួយមកខាងក្រោយ ដោយមានរថយន្តតាក់ស៊ីពណ៌សមួយចតចាំនៅទីនោះជាស្រេច ។ មិត្តយើងដើរមកជិតទ្វាររថយន្ត ហើយគ្រលៀសភ្នែកមើលតៃកុង ដែលពាក់មួកទំលាក់មុខបាំងជិតមិនអាចស្គាល់បាន ទើបគេច្រានមិត្តយើងបញ្ចូលទៅឱ្យអង្គុយខាងក្រោយ ដោយមានមនុស្សពីរនាក់ស្ទុះចេញពីទីងងឹត មកឡើងអង្គុយអែបឆ្វេងស្តាំ ដោយម្នាក់ៗមានកាន់កាំភ្លើងខ្លីមួយផង ហើយមុននឹងរថយន្តស្ទុះចេញ ជនអាថ៌កំបាំងឡើងអង្គុយស្បែរតៃកុង បញ្ចេញសម្លេងគ្រលួចថា ÷

-យកទៅបោះចោលនៅឯជ្រោះភ្នំខាងលើ ដែលយើងរៀបចំហើយនោះណា !

តៃកុងបីតចារីបង្គុយផ្សែងទ្រលោម ហើយបញ្ជារថយន្តបោះពួយចេញពីទីនោះ ដោយបញ្ចេញសូរដូចមេឃរលំ ។ រថយន្តបត់មួយជុំផ្សារ ហើយសំយុងក្បាលទៅកាន់ផ្លូវជាតិឆ្ពោះទៅភ្នំពេញ ដោយនៅក្នុងរថយន្តគ្មានសម្លេងមនុស្សនិយាយរកគ្នាមួយម៉ាត់ឡើយ ហើយក្នុងមួយប៉ប្រិចភ្នែកប៉ុណ្ណោះ រថយន្តមកបង្អង់ល្បឿនពីមុខស្នងការដ្ឋាន បណ្តាលឱ្យជនអាថ៌កំបាំងលាន់មាត់ ÷

-ឆ្កួតអីមកបង្អន់ល្បឿនកន្លែងហ្នឹងហាំ ?



តៃកុងដោះមួកបោះមកក្រោយ ហើយតបដោយគោរព ÷

-បាទ អត់ទោសទៅចុះ សុំចូលឱ្យគេឆែកត្រង់ហ្នឹងមួយភ្លែតសិនទានហាំៗ ......

សំណើចតៃកុងរថយន្ត បណ្តាលឱ្យជនអាថ៌កំបាំងនោះ គំហកកាត់យ៉ាងរហ័ស ÷

-ម៉េចក៏ភ្លើម្ល៉េះ! ប្រយ័ត្នអញបាញ់ចោលមិនស្តាល់គ្នាឯងរើយ !

-កុំសំឡុតគ្នាឯងលោក..... ទុកឱ្យគ្នានៅរស់បន្តិចទៀតសិន,.....

រថយន្តបត់ចូលទៅកាន់មាត់ទ្វារស្នងការដ្ឋាន បណ្តាលឱ្យជននោះស្ទុះកញ្ជ្រោលឡើងដូចត្រូវខ្សែភ្លើងឆក់ លើកកាំភ្លើងឡើងភ្ជង់មករកសៀតផ្កាតៃកុង តែដៃមួយលូកពីក្រោយមកកញ្ឆក់យកអាវុធនោះទៅរហ័ស សឹងមើលមិនទាន់ រឹងរឹតធ្វើឱ្យជននោះរន្ធត់ចិត្តខ្លាំងឡើងថែមទៀត ព្រមជាមួយគ្នានោះសម្លេងមួយបញ្ជាថា ÷

-នៅឱ្យស្ងៀមទៅ កុំអាលសប្បាយពេក ! យើងត្រូវចូលទៅនិយាយគ្នាបន្តិច នៅក្នុងការិយាល័យនោះសិន !

រថយន្តចូលមកចតពីមុខការិយាល័យ ហើយតៃកុងដែលជាតួលោកស្នងការមែនៗនោះ បានបើកទ្វារចេញក្នុងពេលជាមួយអ្នកនៅខាងក្រោយដែរ ។ មិត្តកិត្តិគុណយើង ឧទានដោយសោមនស្ស ÷

-អ៊ូ ! លោកស្នងការ ! បងព្រិល ! បងកែវទេ ? អម្បាញមិញខ្ញុំភ័យប្រហោងពោះប៉ុនក្តិតម្ជុលតែម្តង !

សហជីវិនកែវនិងព្រិល ចាប់អូសជនម្នាក់នោះចេញពីរថយន្ត ហើយបោះខ្នោះដៃស្វ័យប្រវត្តិលាន់គ្រិបជាបន្ទាប់ រួចក៏បណ្តើរចូលទៅ

ក្នុងការិយាល័យភ្នាម ។ ឯមិត្តកិត្តិគុណយើងស្ទុះមកចាប់ដៃលោកស្នងការ ដោយបញ្ចេញញញឹមយ៉ាងស្រស់ ÷

-សូមអរគុណលោកច្រើនណាស់ បើកុំតែបានលោកយល់ដឹងការនេះមុន ប្រហែលជាខ្ញុំត្រូវពួកវានាំទៅបោះទម្លាក់ក្នុងខ្ទះនរកស្រេចទៅហើយ,,,,,,

លោកស្នងការលូកយកម្ជុកពីក្នុងរថយន្តមកពាក់ ហើយបន្ទឹវាចាតប ÷

-គ្រាន់តែកែវប្រាប់ខ្ញុំភ្លាម ខ្ញុំក៏នាំពួកយើងរត់ទៅភ្លាម ស្រាប់តែឃើញមានរថយន្តហ្នឹង នៅចតទីនោះជាស្រេច ពួកយើងសម្ងំពិនិត្យមើលមួយភ្លែត ក៏ឃើញមនុស្សបីនាក់ រត់ចេញពីគុម្ពោតព្រៃខាងក្រោយបារនោះមករវេងជជែកគ្នាខ្សឹបៗក្បែរឡាន ទើបខ្ញុំសន្និដ្ឋានថាពួកវាជាចោរអាថ៌កំបាំងតែម្តង ទើបខ្ញុំប្រើល្បិចចាប់វាទាំងបីនោះបានចងលាក់ទុកក្នុងព្រៃជិតនោះ ជាបណ្តោះអាសន្នសិន ហើយយើងបានក្លែងខ្លួនឱ្យដូចអាបីនាក់នោះ នៅចាំមើលតទៅទៀត ដោយស្មានថាមានមេធំៗ វាចេញមកជិះឡាននេះទៀត នឹងអាលសង្គ្រប់វាទាំងអស់តែម្តង តែមកប៉ះលើគ្នាឯងត្រូវគេចាប់បណ្តើរមកសោះក៏ ចាត់ទុកដូចជាទេពតា បញ្ជូនមកឱ្យបានជួបគ្នាឯងដោយចៃដន្យដូច្នេះដែរ មែនទេលោក !

មិត្តកិត្តិគុណសើច ÷

-ជាសំណាងរបស់ខ្ញុំធំណាស់ ហើយក៏ជាស្នាដៃមួយដ៏អស្ចារ្យរបស់លោកក្នុងរាត្រីនេះដែរ !



-មិនគួរសរសើរខ្ញុំទេ គឺលោកទេតើជាអ្នកធ្វើការបានជោគជ័យក្នុងលើកនេះ...... ប៉ុន្តែ........ ប៉ុន្តែ........

-ប៉ុន្តែយ៉ាងម៉េចលោក ?

-ប៉ុន្តែប្រហែលជាលោកមិនទាន់បានក្រេបរសជាតិទឹកឃ្មុំ ពីនាងសូភីសង្សារបណ្តូលចិត្តនៅឡើយទេមើលទៅ !

នឹកដល់នាងសូភីភ្លាម មិត្តយើងចង់អួលដើមកមួយរំពេច គ្រាន់តែកូនសំបុត្រតូចមួយ ពួកក្លឹបសហ៊ានលូកដៃធ្វើឃាតកម្មយ៉ាងសាហាវបំផុត មិត្តយើងឈ្ងោកមុខចុះព្រមទាំងតប ÷

-សុំលោកឈប់នឹករឿងនាងសូភីនេះទៀតទៅ ព្រោះនាងបានដៅទុកនូវសេចក្តីអាណិតអាសូរមួយ ក្នុងថ្លើមប្រមាត់ខ្ញុំមិនអាចមានថ្ងៃនឹងបំភ្លេចបានឡើយ ហើយជាពិសេសនាងជាស្រីស្លូតត្រង់ ជាមួយខ្ញុំខ្លាំងណាស់ បើសិនជានាងបានដឹងថា នៅក្នុងកញ្ចប់បារីនោះមានសំបុត្រសម្ងាត់ ម្ល៉េះនាងប្រគល់ឱ្យខ្ញុំបាត់ទៅហើយ......

-សំបុត្រអីទៅនៅក្នុងកញ្ចប់បារីលោកកិត្តិគុណ ? លោកស្នងការបញ្ឈាក់កាត់ មិត្តយើងងើបមុខឡើងតបទាំងស្រងូត ÷

-សំបុត្រដែលយើងកំពុងតែខំរាវរកនោះណាំលោក !

-ឥឡូវវានៅឯណា ?

-កញ្ចប់បារីនោះ ខ្ញុំបានញីវាចោលនៅក្នុងបារនោះហួសទៅហើយ ហើយរកនឹករកកន្លែងមិនទាន់ឃើញនៅឡើយទេ ដោយពីយប់មិញនេះមានប្រតិកម្មខ្លាំងពេក.......

លោកស្នងការលើកនាឡិកាមើល ÷

-ម៉ោងទើបតែពីរទេ យើងត្រូវទៅរកកញ្ចប់ថាវីនោះនៅក្នុងបារឱ្យឃើញ ប្រហែលជាមិនទាន់មានពួកវាចាប់ភ្លឹកថា លោកពោះវាចោលនៅក្នុងទីនោះទេមើលទៅ !

-បាទ ! តែលោកមានប្រទះថាវីរ ថៅកែប្ដីនាងនិងចិនហុងកុងពីរនាក់នោះនៅកន្លែងណាទេ ?

-អ្នកតាមដានរបស់យើងបានឃើញ ពួកវាចេញតាមទ្វារក្រោយ ហើយវានាំគ្នាឡើងរថយន្តបរតម្រង់ទៅកំពង់ផែ បាត់ទៅហើយ ហើយអ្នកតាមដានរបស់យើង ក៏កំពុងតែតាមជាប់តទៅទៀតដែរ....

មិត្តយើងងក់ក្បាល ÷

-ឥឡូវត្រូវសួរចម្លើយអាម្នាក់នេះសិន រួចសឹមយើងចូលទៅបាររកសំបុត្រនោះជាក្រោយ ។

សហជីវិនសំខាន់របស់ជាតិទាំងពីរបោះជំហាន ចូលទៅក្នុងការិយាល័យ ដោយដំណើរស្វាហាប់ ស្រាប់តែទិដ្ឋភាពដ៏រន្ធត់មួយបានប្រាកដឡើងនៅចំពោះមុខ.......

-យី ! ម៉េចក៏អីចឹង ? លោកស្នងការភ្ញាក់មាត់

សហមិត្តទាំងពីរនាក់ ហក់ទៅគ្រកងរូបកាយ សហការីកែវនិងព្រិលលើកឡើងជាប្រញាប់ ហើយក្រឡេកភ្នែករកមើលអ្នកទោស ក៏មិនឃើញទៀត ។

មិត្តកិត្តិគុណផ្ដេកក្បាលសៃហ្វព្រិលចុះវិញ ÷

-ពួកយើងទាំងពីរនាក់គ្រាន់តែសន្លប់ទេ សូមលោកជួយព្យាបាលផង ខ្ញុំចេញទៅតាមពួកវាមួយភ្លែត ព្រោះខ្ញុំឮដូចជា មានរថយន្ត



បរចេញទៅកាន់ទិសខាងជើងអម្បាញមិញ........

មិនបាច់លោកស្នងការតបទាន់ មិត្តក្លាហានយើងកញ្ចក់កាំភ្លើងច្រកហោប៉ៅ ហើយច្រានទ្វាររត់ចេញទៅឡើងរថយន្ត បញ្ឆេះម៉ាស៊ីនដាក់លេខពោះពួយ ចេញតាមផ្លូវទៅខាងជើងដូចហោះ ។

រថយន្តមិត្តកិត្តិគុណជ្រែករាត្រី មកដល់ខ្នងភ្នំពីមុខសាលាក្រុងស្រាប់តែមានរថយន្តមួយបត់ចេញពីទីងងឹតម្ខាង វេរមកអែបចន្ទឹមដោយមិត្តយើងពុំបានចាប់ភ្លឹកមុនទាល់តែសោះ ហើយណាមួយអ្នកកាន់ចង្កូតរថយន្តនោះស្ទាត់ជំនាញ ក្នុងការបើកបរក្រៃលែង មិត្តយើងប្រុងលូកដៃទាញកាំភ្លើងពីក្នុងហោប៉ៅ !...... តែ........

ខណៈនោះរថយន្តមួយទៀត បត់ចេញពីផ្លូវមាត់សមុទ្រមកកាត់ទទឹងផ្លូវ ហើយឈប់ពាំងចំពីមុខ បណ្ដាលឱ្យមិត្តយើងជាន់ហ្វ្រាំងលាន់ង៉ោក !

រថយន្តមួយពាំងពីមុខ រថយន្តមួយទៀតអែបជាប់ពីឆ្វេង ហើយបើចង់គេចទៅស្ដាំ ទាល់តែរថយន្តមិត្តយើងមានស្លាបហោះហើរ ដូចរថយន្តរបស់ហ៊្សង់តូម៉ាស បើមិនដូច្នោះទេមិនអាចគេចរួចទៅណាឡើយដោយមានភ្នំចោតរាប់សិបម៉ែត្រចាំងធ្វើជាជញ្ជាំង.... តើមិត្តកិត្តិគុណដ៏ក្លាហានយើងជ្រែកមេឃហែកដីគេចទៅខាងណា ។

## ៣

# មិត្តយើងជាងដែក ក្រែកហ្វូងសត្រូវ

**មិត្តយើង**ត្រូវមនុស្សមួយក្រុម ចងដៃបណ្តើរមកកាន់មាត់សមុទ្រ ដែលនៅទីនោះ មានកាណូតតូចមួយរង់ចាំជាស្រេច ។ ប្រហែលជាដប់នាទីប៉ុណ្ណោះ មិត្តយើងបានមកដល់កោះពស់ ដែលជាទីសំណាក់ការពិសេសរបស់ក្រុមកូឡាបស ហើយដែលជាលើកទីមួយ ដែលមិត្តយើងត្រូវគេចងអូសបណ្តើរបានយ៉ាងស្រួល ។ មិនជាលំបាកយល់ដំរៅចិត្តមិត្តកិត្តិគុណឡើយ ព្រោះកោះពស់នោះហើយដែលជាទីប៉ុនប៉ងរបស់លោក ដើម្បីចូលមករំដោះសហការីផង និងដើម្បីមកពិនិត្យទីកន្លែងពួកជនអាថ៌កំបាំងឱ្យបានជាក់លាក់ផង ។

ជនមិនស្គាល់មុខប្អូននាក់រុញច្រានមិត្តយើង រហូតទៅដល់មាត់ល្អាង ដែលនៅទីនោះមានបុរសម្នាក់ ពាក់ម្ញូកបាំងមុខឈរច្រត់ចង្កេះរង់ចាំជាស្រេច ។ គ្រាន់តែឃើញបក្សពួកគេមកដល់ ជននោះបោះពាក្យភ្វាមថា ÷

-ចាប់បានកូនទន្សាយមកឬទេពួកយើង ?



ម្នាក់និនក្បាលគោរពបន្តិច ព្រមទាំងតប ÷

-ខ្ញុំធ្វើតាមបញ្ជាលោកបានសម្រេចលទ្ធផលល្អណាស់ ហើយពិតជារូបអាម្នាក់ហ្នឹងតែម្តងលោក.......

ជនដែលពួកនោះគោរពបោះចារីចោល ហើយដើរមកជិតមិត្តយើងដោយដំណើរអង់អាច ហើយដំណើរនេះរាងនេះសំដីនេះ មិត្តយើងអាចស្គាល់ច្បាស់ណាស់ គឺគ្មាននរណាក្រៅពីជន ដែលបានធ្វើឱ្យភ្នាក់ងារ នៅក្នុងស្នងការដ្ឋានសន្ទប់ព្រមទាំងគេចដោះខ្លួនមកនោះឡើយ ។

វាមកឈរទីមជើងពីមុខមិត្តយើង ÷

-ហាំ ។ ! កូនទន្សាយពិតជាមានល្បិចគ្រាន់បើមែន ព្រោះបានគេបណ្តោយឱ្យធ្វើអ្វីតាមទំនើងចិត្ត ប៉ុន្តែដល់ទីបំផុតមិនអាចគេចរួចពីដៃព្រានដ៏វាងវៃឡើយ ហើយដើម្បីជារង្វាន់.........

ផាច់ ! ផាច់ ! ផាច់ ! ជនអប្រិយ៍លើកដៃវាត់លើរង្វង់មុខមិត្តយើងលាន់ដូចរន្ទះជះកំហឹងមកទាំងដុំ។ ដែលគេគុំទុកជាយូរហើយ។ មិត្តយើងនៅក្នុងចំណង មិនអាចប្រើកាយវិការណាទប់ទល់ជាមួយបានឡើយ ម្ល៉ោះហើយក៏បណ្តោយឱ្យបច្ចាមិត្តតាមចិត្តចង់ មិត្តយើងគ្រាន់តែផ្ចង់ស្មារតីតំឡើងសាច់ដុំការពារខ្លួន មិនឱ្យទ្រុឌទ្រោមពេកប៉ុណ្ណោះ តែលោកបានធ្វើជាទន់ខ្លួនល្វក់ ដូចជាមនុស្សអន់ខ្សោយណាស់ ដើម្បីឱ្យពួកវាអស់ចិត្ត ។ កុំតែជាប់ចំណង កុំអីប្រហែលជាពួកអាឡាតស៊ីអស់នេះ ធ្លាក់ទឹកសមុទ្រគ្មានសល់មួយទេមើលទៅ ! វាយតប់មិត្តយើង ទាល់តែមានលោហិតស្រក់ពីច្រមុះពីមាត់ ទើបវា

បង្អន់ដៃហើយបញ្ជា ÷

-នាំវាទៅខាងក្នុងដើម្បីរោលភ្លើងសួរវា រកសំបុត្រសំខាន់សិន !

ពួកវាប្អូននាក់កាន់សុទ្ធតែកាំភ្លើងធុនមីត្រៃយ៉ែត ដើរភ្ជង់ជាប់ពីក្រោយយ៉ាងមធ្យ័ត ឯពីរនាក់ទៀតក៏ចាប់អូសមិត្តយើងចូលទៅក្នុងល្ហាង ដែលមានពន្លឺភ្លើងចង្កៀងថ្មព្រោងព្រាត អាចមើលឃើញអ្វីទាំងអស់នៅក្នុងទីនោះ ។ មិត្តកិត្តិគុណយើងលួចវាសភ្នែកទៅកាន់បង្គោលពីរ ដែលមានមនុស្សចងផ្ដោបដូចនំអន្សម ធ្វើឱ្យមិត្តយើងស្លុតចិត្តមិនតិចឡើយ ជនទាំងពីរនោះគ្មាននរណាក្រៅពីភ្នាក់ងារពិសេសរបស់លោកទេ ម្នាក់ក្មេងដែលយើងស្មានថាជាអ្នកនេសាទធម្មតានោះ គឺជាសហការីផ្នែកតាមដានឈ្មោះតារី ហើយម្នាក់ទៀតយើងស្គាល់រួចហើយ គឺសែហ្សភីនដ៏ក្លាហានប្រចាំក្រសួងសម្ងាត់ ។

សហការីទាំងពីរក្រឡេកឃើញ គេបណ្ដើរលោកអធិការចូលទៅក៏ដូចជាធ្លាក់ថ្លើមក្ដុក ទឹកមុខឡើងខៀវបំព្រងដូចស្លឹកចេកមួយរំពេច ហើយនាំគ្នាគេចមុខចេញលែងហ៊ានសម្លឹងមកទៀត ។ បច្ចាមិត្តប្រាប់មិត្តយើង ឱ្យអង្គុយលើកៅអីឈើមួយពីមុខអ្នកជាប់ចំណងទាំងពីររួចវា យកខ្សែចងរឹតរួតយ៉ាងតឹងភ្ជាប់នឹងកៅអីថែមទៀត ។

ជនដែលយើងសំគាល់ថា ជានាយកក្នុងក្រុមនោះ លើកជើងមួយដាក់លើកៅអី ហើយបោះសំនួរម៉ាត់ៗថា ÷

-ឯណាសំបុត្រដែលលោកឯងរកឃើញ នៅក្នុងកញ្ចប់បារីពីព្រលប់ជាមួយមេស្វូភីស្ដីគេនោះ ?

មិត្តយើងស្ដោះទឹកមាត់ឈាមចេញពីមាត់ទើបតប ÷



-មុននឹងនិយាយគ្នា ឱ្យបារីមួយជក់សិនមក !

ជននោះអុជបារីមួយដាក់ក្នុងមាត់មិត្តយើង ហើយតម្លើងសម្លេងសួរទៀត ÷

-ប្រាប់យើងឱ្យត្រង់មក សំបុត្រសម្ងាត់នោះនៅឯណា ? យើងសុំប្រាប់លោកឯងថា បើយោងតាមបញ្ជាពីលើមក គេឱ្យប្រហារលោកឯងភ្លាម មិនឱ្យទុកពេលនិយាយមួយវិនាទីទេណា ! ប៉ុន្តែសំបុត្រនេះជាអាយុជីវិតរបស់ក្រុមយើងនៅក្នុងក្រុងនេះ ទើបយើងមិនទាន់បញ្ចប់ជីវិតលោកឯង ប្រាប់មក !

មិត្តយើងបឺតបារីពីរបីខ្សឹត ហើយផ្លុំវាឱ្យហើរពីមាត់ទៅឆ្ងាយ ទើបតបមួយៗហាក់ដូចជាគ្មានតក់ស្លុត ÷

-យើងពុំបានចាប់ភ្លឹកចំពោះអាថ៌កំបាំង ដែលពួកឯងធ្វើនេះសោះកាលពីពេលព្រលប់យើងបានទទួលបារីមួយកញ្ចប់ ពីដៃនាងស្វូភីមែន ប៉ុន្តែយើងគ្មាននឹកនាសំគាល់ ថាកញ្ចប់នោះគ្មានសារៈសំខាន់អ្វីទេម្ល៉ោះហើយដល់យើងជក់អស់ ក៏បោះកញ្ចប់នោះចោលតែម្ដងទៅ ដល់មកឥឡូវយើងរកនឹកកន្លែងដែលបោះចោលនោះ មិនទាំងឃើញទៀតផង......

-បានសេចក្ដីថាលោកឯងនៅតែលាក់ទៀតដដែល លោកពិតជាមិនព្រមប្រាប់មែនឬអី ? ជននោះសំឡុតខ្លាំងៗ បណ្ដាលឱ្យពួកអ្នកកាន់កាំភ្លើងទាំងប៉ុន្មាន ប្រុងប្រៀបខ្លួនជាងមុនទ្វេឡើងទៀត ។

-យើងមិនដឹងមែន! ហើយមិនទាំងនឹកឃើញថា កញ្ចប់បារីនោះមានយីហោស្អីផងទេ........

-នៅតែលាក់ទៀត ! វាគំហក

-ព្រោះមិនដឹង ! មិត្តយើងគំហកតប

-បើអីចឹងយើងត្រូវតែប្រើធម៌ក្ដៅជាមួយ........

-តាមចិត្ត យើងឥតព្រីទេ ! ហើយចិត្តយើងបានទាំងប្ដេជ្ញាហើយស្រេចថា នឹងកំទេចពួកឯងឱ្យក្លាយជាធូលីក្នុងពេលបន្តិចទៀត......

-ហាំៗ! ហាំៗ ! បើលោកឯងធ្វើបានវាមានទៅទាស់ខុសអី..... .... ហើយចាំមើលយើងឯណេះវិញហាំ !

ថាហើយជននោះដកកាំបិតពីក្នុងស្រោមស្បែកជើង ដ៏មានមុខសស្លាចគួរឱ្យព្រឺខ្លួន រួចវាដាក់ឆ្អើរពីលើភ្លើងចង្កៀងថ្មជិតនោះ ព្រមទាំងបោះសំដីទៀត ÷

-ដែកនិងភ្លើងល្អណាស់ បើប៉ះគ្នាហើយនឹងបង្កើតបានជាអាវុធមួយសម្រាប់ប្រើក្នុងការសួរចម្លើយមនុស្សរឹងទទឹងដូចលោកឯងនេះ!

-តែចិត្តមនុស្សដូចយើង រឹងជាងដែក និងក្ដៅជាងភ្លើងហ្នឹងទៅទៀត បើមិនដូច្នោះទេក្រសួងមានសមត្ថកិច្ច ច្បាស់ជាមិនប្រគល់ភារកិច្ចដ៏ធ្ងន់នេះ ឱ្យមកយើងបំពេញទេរ៉ើយ........

ផាំងៗ ! ជនមិនស្គាល់ឈ្មោះបន្ថែមលើវង្ង់មុខមិត្តយើងពីរបីដៃទៀត បណ្ដាលឱ្យភ្នែកបែកអំពិលអំពែក ត្រចៀកហ៊ឹងសឹងស្ដាប់អ្វីលែងឮ ។ គួរឱ្យអាសូរណាស់ ក្នុងមួយរាត្រីនេះលោកអធិការយើងត្រូវមុជជ្រែកកាត់គ្រោះថ្នាក់ធ្ងន់ៗរាប់មិនអស់ ប៉ុន្តែក្នុងចិត្តលោកគ្មានថ្ងូរបន្តិចឡើយ ហើយសប្បាយចិត្តនឹងទទួលថែមទៀតផង ដោយលោកគិតថា គ្រោះថ្នាក់តូចធំតែងកើតមានឡើងជាស្ពានរនៅជុំវិញ



ខ្លួនលោក ដែលកាន់នាទីជាអ្នកការពារសេចក្ដីសុខសាន្តត្រាណ និងសេចក្ដីចំរើននៃប្រទេសជាតិ ជាពិសេសលោកចាត់ទុកជាមេរៀនសម្រាប់រូបលោក ដែលជាអធិការនៃក្រសួងសន្តិសុខជាតិយើងផង ។

លោកអធិការកំសត់យើង ស្រវាំងភ្នែកអស់មួយសន្ទុះ ទើបប្រឹងប្រមូលស្មារតីបានមកដូចប្រក្រតីវិញ ហើយស្រាប់តែយល់ចុងកាំបិតដ៏ ស្រួចនិងក្រហមដូចរងើកភ្លើង លើកឡើងមកជិតដល់ភ្នែកជាស្រេច បណ្ដាលឱ្យសហការីលោកទាំងពីរ រន្ធត់ស្ទើរបាត់ព្រលឹងពីខ្លួន ឯរូបលោកវិញក៏ខំបើកភ្នែកសម្លឹងចុងដែកក្រហមនោះ គ្មានប៉ប្រិចសោះ ដូចគ្មានស្លុតបន្តិច ។ ចុងកាំបិតជះចំហាយក្ដៅភាយៗមកលើវង្ង់មុខកាន់តែជិតមកៗជាលំដាប់ ដោយដៃមហាឃាតករមិនស្គាល់ឈ្មោះនេះ ចេះតែរុញចំមកប្រាថ្នាឱ្យមិត្តយើងស្លុតភ័យនឹងអាលប្រគល់សំបុត្រអាថ៌កំបាំងនោះឱ្យវាវិញ ។

វារុញកាំបិតលឿនជាងមុន រិប ! តែ.......

-លោក ! លោក ! មានភ្លើងឱ្យសញ្ញាពីក្រោមមក ! សញ្ញាបែបនេះគេឱ្យដឹងថា មានមនុស្សចំឡែកឡើងមកហើយលោក ! សម្លេងអ្នកយាមនៅក្រៅល្ពាងស្រែកមកខ្លាំងៗ ដូចជាទប់ដៃមហាឃាតករនេះ មិនឱ្យរុញខ្វេះភ្នែកមិត្តជាទីស្នេហានៃយើងបាន ហើយជាបន្ទាន់ វាបោះកាំបិតចោលប្រូស រួចងាកមកសួរយ៉ាងរហ័ស ÷

-គេឱ្យសញ្ញាមកប៉ុន្មានដងហើយ ?

-ញាប់រន្ធើនរាប់មិនទាន់ទេ ប្រហែលជាមកជិតដល់ណាស់ហើយពួកយើងត្រូវប្រុងប្រៀបខ្លួនបន្តិច..... !

ចប់ប្រយោគអ្នកយាមខាងក្រៅសឹងមិនទាន់ ជននេះបានធ្វើសញ្ញាឱ្យសហការីវាទាំងបួននាក់ ដែលឈរកាន់មីត្រៃយ៉េតជិតនោះ ឱ្យរត់ចេញទៅក្រៅ ហើយចំណែកវាមុននឹងរត់ចេញទៅ វាបានងាកមកផ្តាំមិត្តយើងដោយសង្កត់ពាក្យធ្ងន់ៗ ÷

-អនុញ្ញាតឱ្យលោកឯងសម្រេចចិត្តមួយខណៈសិន ហើយដល់យើងឡើងមកវិញ នៅតែមិនព្រមប្រគល់សំបុត្រនោះឱ្យយើងទេ យើងនឹងធ្វើជីវិតលោកឯងទៅទុកនៅស្ថានបាតតាលហើយណា៎ !

រួចវាដកកាំភ្លើងខ្លីពីហោប៉ៅរត់ចេញត្រុយទៅ បាត់ស្រមោល ។ ដូច្នេះនៅក្នុងល្អាងកោះទាំងមូល នៅសល់តែមិត្តយើងបីនាក់ជាប់ចំណងប៉ុណ្ណោះ ក៏ដូចជាទុកឱកាសឱ្យមិត្តយើងលួមលកលៃមធ្យោបាយដោះខ្លួនដែរ ប៉ុន្តែធ្វើម្តេចកើត បើសុទ្ធតែមានខ្សែរឹតរួតខ្លួនជាប់ជាងត្រីជាប់ជុចទៅទៀតយ៉ាងនេះ ។

លោកកិត្តិគុណងើបមុខទៅរកសហការីទាំងពីរ ÷

-ម៉េចស្រួលខ្លួនទេពួកយើង ?

សៃហ្វភីន ហារមាត់តបមួយៗមកវិញ ÷

-បែបរកស្រួលមិនកើតទេលោក បើវាចងឆ្កាងរកតែកម្រើកខ្លួនបន្តិចយ៉ាងនេះ....... មើលទៅទ្រាំយូរទៀតមិនរួចទេ....... មុខជាស្លាប់ចោលម៉ែមីកាទូចហើយខ្ញុំ........

-ទ្រាំទៅបងភីន....... ពួកក្រសួងយើងវាត្រូវតែអីចឹង...... មានកំសត់ហូរទឹកភ្នែក មានសប្បាយភ្លេចប្រពន្ធកូនម្តងៗដែរ យើងជាប់ចំណងក្នុងការបំពេញបេសកកម្ម ទោះបីយ៉ាងណាក៏យើងបានឈ្មោះ



ថាជាអ្នកធ្វើការ ជាអ្នកលើកតំកើងករណីយកិច្ចយើងដែរ.......

សហការីម្នាក់ទៀតស្ងួតបំពង់ក និយាយលែងចេញទៅហើយ គ្រាន់តែបើកភ្នែកសម្លឹងមកលោកអធិការភ្រឹកៗប៉ុណ្ណោះ ហើយផ្ទួនកាលធ្វើមុខស្ពុយប៉ែដូចមនុស្សអត់បាយ ជាងមួយរយឆ្នាំមកហើយដូច្នោះ ។ មិត្តកិត្តិគុណសម្លឹងនាយអាយរកមើលឧបករណ៍ បច្ចាមិត្តនៅក្នុងទីនោះ ក្រែងមានអ្វីគួរយកមកប្រើដោះស្រាយក្នុងគ្រាអាសន្ននេះ ។ វេពេចនោះលោកឧទានខ្លាំងៗដូចជាសោមនស្សពន់ពេកណាស់ ។

-ខ្លួនទីពឹងខ្លួនពួកយើង ! គ្មានអ្នកណាគេមកជួយយើងឱ្យរួចបានទេ........

រួចលោកសាកលើកកៅអីដើរយឺតៗ មករកគុដែលមានតំកល់ចង្កៀងថ្មឆេះធ្លោជិតនោះ ។ លោកខំលើកដៃទាំងពីរដែលជាប់ចំណងខ្សែពួរ លូកទៅរកភ្លើងទាំងបែកញើសស្រោក់ ខំណាស់តែសង្ឃឹមតិចណាស់ ប៉ុន្តែសេចក្តីព្យាយាមនៅតែខំសាកតទៅទៀត ។ លូកចំអើតដាក់ដៃជិតដល់ភ្លើងទៅហើយ ស្រាប់តែមានស្នូរជើងដូចមនុស្សដើរនៅខាងក្រៅ បណ្តាលឱ្យលោកខំយោងកៅអីត្រឡប់មកកន្លែងដដែលវិញ ប៉ុន្តែស្នូរនោះក៏បាត់សូន្យឈឹងទៅវិញ លោកអធិការយើងលេបទឹកមាត់មួយក្អឹក ហើយក៏ដើរសន្សឹមៗទៅរកភ្លើងទៀត ម្តងណេះលោកប្រឹងលើកដៃទាំងចំណង ដាក់ដុតភ្លើងដោយពុំមានទឹកខ្លាចឆេះរលាកសាច់ឡើយ ។ ព្រះអគ្គីមានមេត្តាក៏ចាប់ឆេះខ្សែចំណង នោះម្តងមួយសរសៃៗជាលំដាប់ ប៉ុន្តែយើងឃើញញើស

ប៉ុនៗគ្រាប់ពោត អណ្តែតឡើងពាសពេញផ្ទៃមុខលោក ចួនកាលឃើញលោកខាំមាត់ញញួញញួចដោយមកពីភ្លើងឆេះរោល ដល់កដៃលោកឡើងពងស្បែកប៉ុនៗមេដៃមេជើង សឹងតែទប់ទៀតលែងបាន តែចិត្តប្តេជ្ញា តស៊ូយ៉ាងស្វិតស្វាញពុំបាន ធ្វើឱ្យលោករារែកចិត្តខ្វាចការឈឺចាប់នេះឡើយ លោកខំធ្មេចភ្នែក អត់ដង្ហើមស្ទើរតែស្រែកទ្រហោរហៅម៉ែឪ ប៉ុន្តែការឈឺចាប់ប៉ុណ្ណោះមិនបានមួយភាគ ដែលលោកឈឺចាប់ខាងផ្លូវចិត្ត ចំពោះអំពើទុច្ចរិតនៃពួកពាលទាំងនេះឡើយ ម៉្លោះហើយលោក ស៊ូតែបណ្តោយឱ្យព្រះអគ្គីឆេះសាច់ឡើងឈៀមឡប់ ពុំព្រមថ្ងូរមួយអឺះដាច់ខាត ចួនកាលលោកប្រឹងញញឹមទៅរកសហការីទាំងពីរ ដើម្បីជួយលើកទឹកចិត្តឱ្យក្លាហាន ទាំងចិត្តញាប់ញ័រឥតគណនា ។

-ជិតសម្រេចហើយ....... គុណបុណ្យលោកជួយ....... ទឹកដោះម្តាយថ្ងៃ....... បារមីនៃព្រះស្វេតច្ឆ័ត្រ យើងមិនអាចស្លាប់ងាយៗទេ...

ភ្លាមនោះដៃលោកបានរួចពីចំណងដូចប្រាថ្នា ក៏លូកចូលទៅក្នុងអាវទាញបន្តោងខ្សែកមាស ប៉ុនពីរធ្នាប់ប្រវែងប្រហែលមួយថ្នាំងដៃចេញមកហើយចុចគន្លឹះម៉ាច់ ! មុខកាំបិតតូចមួយលៀនមកខាងក្រៅសស្វាច បណ្តាលឱ្យសហការីទាំងពីរ ឧទានឡើងយ៉ាងសោមនស្ស÷

-ជយោលោកអធិការកិត្តិគុណ ! ពួកយើងបានរួចពីស្លាប់ហើយ!

រំពេចនោះ លោកកាត់ចំណងខ្លួនបានរបូតពីកៅអីទៀត រួចស្ទុះក្រោករលាស់ខ្លួនប្រាណរៀបចំសរសៃរឱ្យបានស្រួលឡើងវិញ ព្រមទាំងលើកកដៃមកពិនិត្យឃើញខ្លោចសាច់ របកស្បែកឡើងសស្កុស។



ថៃមទាំងក្រហល់ក្រហាយ ដូចគេប្រឡាក់អំបិលស្ទើរទ្រាំមិនបាន ។ ក្នុងពេលដែលលោកងាកខ្លួន ប្រុងនឹងជួយកាត់ចំណងសហការីទាំងពីរហើយស្រាប់តែ.......

-កុំកម្រើក ! នៅឱ្យស្ងៀម បើមិនស្លាប់ទេប្រយ័ត្នតែស្ទើងរើយ !

មិត្តយើងភ្ញាក់ដូចគេកន្ត្រាក់ ទម្លាក់ពីលើមេឃ ទុចជំហានឈប់ស្ងៀម ព្រមទាំងលួចងៀងភ្នែកមើលទៅម្ចាស់សម្លេង ដែលកំពុងឈានជើងចូលមក ដោយភ្ជង់មីត្រៃយ៉េតចំមកយ៉ាងអង់អាចផង......

-លើកដៃលើងលើភ្លាម ! ប្រយ័ត្នអ្នកបាញ់បំបែកក្បាលរើយ !

មិត្តយើងឈរបែរខ្នង លើកដៃទាំងពីរឡើងសន្សឹមៗ ហើយខំផ្ទៀងត្រចៀកស្តាប់ទៅក្រៅ ក្រែងមានពួកវាចូលមកទៀត តែពុំមានឮអ្វីសោះ ដូច្នេះមិត្តយើងយល់ថា អានេះគេទុកឱ្យនៅយាមល្បាងតែម្នាក់ឯងគត់ប៉ុណ្ណោះ ។ វាដើរមកឈរពីក្រោយ ដោយរុញចុងកាំភ្លើងមកផ្ទល់ខ្នងមិត្តយើងផង.......

-ពូកែគ្រាន់បើរើយ ! ដាប់ចំណងប៉ុណ្ណឹងហើយ នៅរៀ្បចទៀតហាំៗ !

-មិនបាច់គ្រាន់តែចំណងប៉ុណ្ណោះទេ សូម្បីតែគ្រាប់កាំភ្លើងគាត់ឯងនេះ ក៏មិនអាចរារាំងយើងបានដែរអាសំឡាញ់ !

-ហាំៗ ! ហាំៗ ! វត់រួចនឹងគ្រាប់កាំភ្លើងអញផងឬ ?

-ពិតណាស់អាសម្លាញ់ ! មិត្តកិត្តិគុណតបគ្មានស្ទុតចំពោះចុងកាំភ្លើងបច្ចាមិត្ត ដែលភ្ជង់ជាប់ពីក្រោយនេះឡើយ ។

វារុញចុងកាំភ្លើងសង្កត់លើខ្នងមិត្តយើងឱ្យធ្ងន់បន្តិចទៀត ÷

-គ្រាន់បើសាកលមើល តេជគុណ !

-ឯងប្រុងខ្លួនហើយឬនៅ ?

-រួចស្រេចហើយ ! ឱ្យតែតេជគុណឯងហ៊ានកម្រើកបន្តិច ច្បាស់ជារយះខ្លួនជាមួយរយចំរៀកឥឡូវ.......

-យើងសាកឱ្យមើលបាន ! អីចឹងប្រុង........

ភិប ! ភិប ! រហ័សដូចផ្លេកបន្ទោរ មិត្តយើងវាត់ដៃស្តាំមកកៀសចុងកាណុងវាទៅម្ខាង ហើយដៃឆ្វេងក៏កាប់ចំកណ្តាលមុខវាយ៉ាងអស់ទំហឹង ទាំងនាំខ្លួនអានោះអណ្តែតធ្លោទៅប៉ះនឹងគុលាន់ភឹង! បណ្តាលឱ្យវាខូចជំហរដោយពុំដឹងខ្លួន ។ អានោះប្រមូលស្មារតីចាប់កាំភ្លើងតម្រង់មករកទ្រូងមិត្តយើងម្តងទៀត តែវាយឺតបន្តិចទៅហើយ ដោយលោកអធិការមានកាយវិការ រហ័សជាងព្រួញទិព្វទៅទៀត ហក់ទៅព្រលែងវាមួយជើងចំកំភួនដៃ បណ្តាលឱ្យប៉ុងអាវុធទៅធ្លាក់ប្រហែលបីម៉ែត្រ ហើយឆ្លៀតឱកាសនោះមិត្តយើងវាត់បន្ថែមមួយជើងទៀត ចំចង្ការលាន់តែផាំង ! ដងខ្លួនវាហើរដូចសំឡីទៅផ្ទប់នឹងជញ្ជាំង ។ វាខំស្ទុះក្រទីក្រទាមកទៀត តែលោកអធិការកិត្តិគុណដែលកំពុងតែមានជំហរល្អស្រាប់ ក៏ហក់ទៅបុកដើមទ្រូងវានឹងក្បាលជង្គង់ ព្រមទាំងវាត់ដៃឡើង ភិប ! ភិប ! ដូចជាបញ្ជូនឱ្យវាខ្ទាតទៅបោកនឹងជញ្ជាំងថែមទៀត ។ ស្រេចល្មម ! ដងខ្លួនអានោះសំយ៉ុងទន់បន្តិចម្តងៗ រហូតដល់រលំគ្រេងបាត់មាត់ឈឹង ។ មិត្តយើងដកដង្ហើមស្រូបខ្យល់ឱ្យចូលសួតជាថ្មី ទៅរើសកាំភ្លើងមីត្រៃយ៉េតមកកាន់ ហើយរត់ទៅបង្គោលសហការីទាំងពីរ ។



សែហ្វភីនអរណាស់ ក៏ឱទានឡើង ÷

-លោកអត់មានត្រូវរបួសទេឬ ?

គីរីសហការីក្មេងបន្ថែម ÷

-ខ្ញុំខំប្រឹងជួសលោកឡើងបែកញើសស្រាក់ៗតែម្តង...... លោកពិតជាអ្នកប្រដាល់ឯក កម្ររកអ្នកណាប្រដូចបានណាស់.......

មិត្តកិត្តិគុណលើកដៃជូតមុខ រៀបសក់បន្តិចទើបតបវិញទាំងញញឹម ÷

-កុំអាលអួតលើកគ្នាឯងនៅក្នុងរូងខ្លាឱ្យសោះ ! យើងត្រូវគិតដោះខ្លួន ក្នុងឱកាសដ៏ប្រសើរនេះសិន......

លោករើសកាំបិតដែលចោរបោះអម្បាញមិញ មកកាត់ចំណងឱ្យសហការីទាំងពីរ ដោយចិត្តរីករាយជាអតិបរមា សែហ្វភីនរលាស់ដៃរលាស់ជើងបន្តិចហើយក៏ទទួលកាំភ្លើងមីត្រៃយ៉េត ពីដៃលោកអធិការមកកាន់ ដោយនៅពេលនោះមានស្នូរជើងនិងមាត់មនុស្សជជែកគ្នាឆ្លោះ តម្រង់មកល្ហាងមិត្តយើងនេះ ។

-យើងត្រូវប្រើល្បិចចាប់វាឱ្យបានទាំងអស់ គឺយើងត្រូវធ្វើដូចជានៅជាប់ចំណងដដែល ហើយដល់ពួកវាមកជិត សឹមយើងចាត់ការយល់ព្រមទេ ?

-ស្រួលហើយទាន ! ព្រលះវាឱ្យហិនហោចម្តងទៅមើល ពួកអាឧក្បាតអស់ហ្នឹង ! សែហ្វភីននិងគីរីហក់ទៅឈរតោងបង្គោលវិញដូចដើម ឯលោកក៏ដាក់ខ្លួនអង្គុយលើកៅអី ទាញខ្សែមករុំខ្លួនបន្តិចរួចដៃដែលបោះទៅក្រោយ ហាក់ដូចជាជាប់ចំណងនោះ សម្រាប់

កាន់កាំភ្លើងខ្លី ។

រំពេចនោះ ពួកវាពីរនាក់កាន់មីត្រៃយ៉ែត ដើរឆ្កុយចូលមកដោយ ម្នាក់បន្ទឺសំដីថា ÷

-អានោះគេឱ្យនៅយាមល្ហាង ចុះឥឡូវវាប្រកាច់ទៅឯណាបាត់ទៅ ! យីអានេះសមតែបាញ់បណ្ដែតទឹកចោលមែនតែម្ដង.......

-ឱ្យតែវាហ៊ានល្មើសនឹងបញ្ជាយ៉ាងនេះ មិនយូរមិនឆាប់ទេ នឹងត្រូវតែហោងមិនខាន កុំគិតអី ទៅមើលអ្នកទោសមួយភ្លែតសិន !

វាទាំងពីរនាក់ដើរមករកមិត្តយើង ដោយពុំបានប្រុងប្រយ័ត្នអ្វីបន្តិចឡើយ ព្រោះវាអាងថាមិត្តយើងទាំងបីជាប់ចំណងស្រាប់ ។ អាម្នាក់មកឈរជិតលោកអធិការ ហើយម្នាក់ទៀតមកឈរជិតមិត្តយើងទាំងពីរ ដោយចោលភ្នែកសម្លឹងមិត្តយើងតាំងពីចុងជើងដល់សក់ក្បាល.... ស្រាប់តែអាម្នាក់ឈរជិតលោកអធិការបើកភ្នែកធំៗ ÷

-វា........ វាដូចជារបូតពីចំណង........ ហើយ.......

ភិប ! ភិប ! ប្រូស ! បញ្ចប់ភេរវសញ្ញាមិនទាន់ជាដាច់ខាតព្រោះមិត្តទាំងបីបានប្រុងខ្លួនមុនស្រេចហើយនោះ ក៏វាយវាចំកញ្ចឹងកមួយកាំភ្លើងម្នាក់ប្រកាច់ត្រឡិល ជ្រុះកាំភ្លើងពីដៃរលំផ្កាប់មុខគ្រេងៗជាបន្ទាន់ ។ មិត្តយើងរើសកាំភ្លើងមកកាន់គ្រប់ដៃ ហើយអូសវាទាំងបីទៅចងភ្ជាប់នឹងបង្គោលវិញម្ដង........

-ចាំស្អែកសឹមយើងឱ្យគេប្រមូលពួកវាយកទៅស្នងការដ្ឋាន ឥឡូវយើងមានការចាំបាច់ ត្រូវតែរុករើមើលកន្លែងនេះ តើពួកវាមានលាក់អ្វីខ្លះទៅ ! លោកអធិការពោលទៅកាន់សហការីទាំងពីរ ។



សែហ្សភីន សម្លឹងមើលជុំវិញខ្លួនបន្តិចទើបតប ÷

-ឡាំងចំនួនសាមសិប ដែលវាគរទុកកន្លែងនុះ ឥឡូវវាជញ្ជូនយកចេញទៅអស់ហើយ មិនដឹងជាឡាំងស្អីទេលោក !

មិត្តយើងបើកភ្នែកធំៗ ÷

-មានឡាំងទុកនៅកន្លែងហ្នឹង

-បាទ ! ប៉ុន្តែមិនដឹងថាវាជញ្ជូនយកទៅខាងណាហើយទេ......

-ឡាំងទាំងនោះពិតជាមានរបស់សំខាន់ មិនខានទេ ! គួរឱ្យស្ដាយណាស់ មិនដឹងជាវាប្ដូរយកទៅទុកកន្លែងណាវិញហ្ន៎ !

គីរីចោលភ្នែកទៅក្រៅល្ហាងបន្តិច ទើបងាកមកតបវិញ ÷

-បើតាមខ្ញុំយល់ បែបវាមិនទាន់នាំទៅឆ្ងាយនៅឡើយទេលោក ! គួរតែយើងរុករកក្នុងល្ហាងនេះឱ្យសព្វគ្រប់សិនទៅមើល........

មិត្តយើងគិតបន្តិច ទើបតបវិញ ÷

-ត្រូវនាំវាទៅសួរចម្លើយ ទើបងាយដឹងថាឡាំងទាំងនោះប្ដូរកន្លែងទៅខាងណា ហើយក្នុងឡាំងនោះមានអ្វីផង.......

ប៉ុង ! ប៉ុង ! ប៉ុង ! មិនទាន់ទាំងបានបញ្ចប់ប្រយោគស្រួលបួលផង សូរកាំភ្លើងក៏លាន់ឡើងនៅខាងក្រៅល្ហាងកគ្រើកទឹកសមុទ្រ ហើយសូរបែបនេះមិត្តយើងស្គាល់ច្បាស់ ថាមានការប្រយុទ្ធគ្នាទៅវិញទៅមកតែម្ដង ។ លោកអធិការបញ្ជាឱ្យសហការីទាំងពីរហក់ចេញទៅមុន បន្ទាប់មកលោកដើរពន្លត់ភ្លើងទាំងអស់ ទើបរត់ចេញក្រៅតាមក្រោយ ។ លោកអធិការចាប់មីត្រៃយ៉ែតមកកាន់ ហើយប្រាប់សហការីថា ÷

-នៅចាំខ្ញុំខាងលើនេះសិនហើយ ទុកឱ្យខ្ញុំចុះទៅមើលពួកវាបន្តិចដើម្បីឱ្យដឹងថាតើពួកវាបាញ់ឆ្លើយឆ្លងជាមួយអ្នកណា ?

-បែបជាមួយអ្នករាជការយើងហើយលោក (គីរីជំរាបបញ្ជាក់)

លោកអធិការងក់ក្បាលយល់តាមសំដីគីរីដែរ ហើយក៏បោះជំហានដើរលបៗ ចុះទៅកាន់ជើងកោះដោយកាយវិការស្រាលៗ ដូចខ្លាលបចាប់ម្រឹគនៅក្នុងព្រៃ ។ មួយភ្លែតប៉ុណ្ណោះ មិត្តយើងបានមកដល់ចន្លោះថ្មមួយកន្លែង ដែលផ្សែងរំសេវរសាត់មកឈៀមឡប់ អាចឱ្យមិត្តយើងយល់បានថា អ្នកកាន់កាំភ្លើងនៅជិតបង្កើយនេះ ។ លោករំពៃមើលសព្វកៀនកោះ តែដោយពេលនោះមេឃខ្មៅគ្មានរស្មីបន្តិចសោះ ទើបមិនអាចឱ្យមិត្តយើងមើលឃើញអ្វីៗឡើយ ក្នុងខណៈដែលមិត្តយើងលបចុះសន្សឹមៗទៅក្រោមទៀតនោះ ស្រាប់តែលេចសម្លេងមួយសួរពីក្រោយខ្នងមក ÷

-អ្នកណាដើរហ្នឹង ?

មិត្តយើងងាកភ្លែតយ៉ាងរហ័ស ÷

-គ្នាឯងទេ..... ពួកយើងបំបែកគ្នាទៅណាខ្លះហើយ ?

ស្រមោលម្នាក់ដើរចេញពីកន្លៀតថ្ម មករកមិត្តយើងដោយមានទាំងកាន់កាំភ្លើងមីត្រៃយ៉ែតផង ÷

-អ្នកណាគ្នាឯង ប្រាប់ឈ្មោះផងមកមើល៍ !

មិត្តយើងឈានជើងទៅទល់មុខ ÷

-កុំអាលសួរ ពួកគេឡើងមកទៀតហើយ......

ជននោះមានការសង្ស័យ ក៏ប្រញាប់ដកពិលពីក្នុងហោប៉ៅបំរុងនឹង



ផ្ទុះមើលមុខទៅហើយ តែធ្វើម្ដេចនឹងទាន់ បើខ្លាយើងប្រុងខ្លួនជាស្រេចហើយនោះ ក៏ស្ទុះភ្លែតលើកជើងទាត់ទម្លាក់ពីដៃវាផាំង ! ហើយលាបាតដៃកាប់មុំាងលើកញ្ជឹងកវាបន្ថែមទៀត អានោះលាន់មាត់អ៊ឹក....... ដួចជ្រូកត្រូវព្រនង់ សំយ៉ុងក្បាលចុះបន្តិច មិត្តយើងលើកក្បាលជង្គង់បុកបញ្ច្រាសចង្កា សើយទៅលើយ៉ាងអស់កំហឹងបណ្ដាលឱ្យដងខ្លួនវាប៉ើងទៅបោកផ្ទប់នឹងថ្ម ធ្លាក់កាំភ្លើងពីដៃ ហើយក៏រលំប្រួសបាត់មាត់តែម្ដងទៅ ។ លោកកិត្តិគុណកំពូលអ្នកប្រយុទ្ធដៃដែក បង្វិលខ្លួនហក់ទៅក្រោមទៀតជាបន្ទាន់ ទើបតែបានប៉ុន្មានជំហានស្រាប់តែមានស្នូរកាំភ្លើងផ្ទុះក្បែរខ្លួន ប៉ុង ! លោកភ្ញាក់ព្រើតវាត់ភ្នែកយ៉ាងរហ័សទៅរករន្ទះភ្លើងអម្បាញមិញ ក៏ឃើញមនុស្សម្នាក់កំពុងតែឱនងើបៗ នៅពីក្រោយថ្មមួយផ្ទាំង ។ មិត្តយើងដើរស្រាលៗ ដូចស្រមោលទៅឈរពីក្រោយខ្នងវា ÷

-ពួកយើងបែកខ្ញែកទៅណាអស់ហើយ ?

គាត់នោះមិនបានងាកមកមើលមនុស្សពីក្រោយខ្នងទេ ព្រោះវាកំពុងតែខំសម្លឹងទៅស្រមោលមនុស្ស ដែលរត់ភ្លឹបភ្លែតៗនៅចម្ងាយប្រហែលម្ភៃម៉ែត្រប៉ុណ្ណោះ ហើយតបដោយសំលេងគ្រលៗ ÷

-មិនដឹងទៅខាងណាខ្លះទេ....... តែពួកគេកាន់តែឡើងមកច្រើនហើយ...... ប្រហែលជាព័ទ្ធកោះយើងជាប់ទៅហើយមិនដឹង.......

-ពួកណាឡើងមកហ្នឹង ? មិត្តយើងខ្សឹបសួរទៀត

-ពួកប៉ូលីសហាំ....... អេ....... អ៊ុំ......គាត់ឯងដូចជាមនុស្ស......

នាយនោះងាកមុខមករកមិត្តយើងភ្ញាម..... តែ..